សមាគមបុគ្គលិកសិក្សាខ្មែរ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

២៦

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត ~ សំភារៈ

# ទស្សនាវដ្តី គ្រូបង្រៀន




ខែ មករា - កុម្ភៈ - មីនា ឆ្នាំ ២០០៦

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)

# មាតិកា

**គណៈកម្មការរៀបរៀង និង និពន្ធ**

- លោក កែវ យ៉ារ
- លោក ជុំ ហ៊ីន
- លោកស្រី គុយ ផល្លា
- លោក ស្វាយ ទិត្យ
- លោកជំទាវ ប៉ែន ណាវុល
- លោក ថោង បូរ៉ាន់
- លោក កៅ ជឿន
- លោកស្រី ប្រាក់ សុលីដា
- លោកស្រី ឧន់ សុភ៌ុ
- លោក ប៉ែន សារុន
- សមាជិក-សមាជិកាស.ប.ស.ខ

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អាង
- លោកជំទាវ ហួរ ស៊ីរី
- លោក ស៊ុង រ៉ាន់ថន
- លោកបណ្ឌិត អ៊ឹម កុច
- លោក សួង សារុន
- លោក ស៊ិន ស៊ីម

**វិចិត្រករ**

លោក ប៉ាន់ ត្រា

**ការីកុំព្យូទ័រ**

កញ្ញា ម៉ៃ សុធី

**ក្របខាងក្រៅ**

- **ពីមុខ:** ការសម្ដែងសិល្បៈរបស់កុមារថ្នាក់មត្តេយ្យសិក្សាអនុវត្តក្នុងពិធីបវេសនកាល។
- **ពីក្រោយ:** ស្ត្រីខ្មែរទៅដើមសតវត្សទី២០


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| ២ | ទំរង់នៃការធ្វើសេចក្ដីសំរេច | ២ |
| | **ចំណេះដឹងទូទៅ** | |
| ៣ | អំពីពូកស្នួច | ៣ |
| ៤ | ទំនៀមទំលាប់ និងប្រពៃណីខ្មែរ ស្ដីពីការអប់រំចរិយាសម្បត្តិ (ត) | ៦ |
| ៥ | តើព្រះពុទ្ធសាសនាអាចនឹងសាបសូន្យមែនរឺ? | ៩ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៦ | វិន័យ និងសមត្ថភាពគ្រូ | ១២ |
| ៧ | ទស្សនៈអប់រំ និងការស្វែងយល់ចំពោះកុមារនៅក្នុងគ្រួសារ(តចប់) | ១៦ |
| | **វិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា** | |
| ៨ | ប្រទេសដែលបង្កើតសំភារៈបរិក្ខាមុនគេបង្អស់ក្នុងអំឡុងពេលបដិវត្តន៍ឧស្សាហកម្ម | ១៨ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ៧ | វិធីបង្រៀន និងកម្មវិធីសៀវភៅសិក្សាភាសាខ្មែរនៅបឋមសិក្សាបំពេញវិជ្ជាពី ឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០ (ត) | ១៩ |
| ៨ | ការណែនាំគរុកោសល្យ (ត) | ២២ |
| ៩ | កំណែលំអសាលារៀន : ជំហានដំបូងមួយ | ២៥ |
| ១០ | ភាសា : ប្រភពភាសាបាលី និងភាសាសំស្ក្រឹត | ២៧ |
| ១១ | ល្បែងទាយលេខបូក | ២៩ |
| ១២ | គណិតវិទ្យា : ការស្ទាបស្ទង់ | ៣០ |
| ១៣ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ៣១ |
| | **វាទីកំណាព្យ និង កំសាន្ត** | |
| ១៤ | ការអប់រំក្នុងគ្រួសារ | ៣៤ |
| ១៥ | សម្បទាទាំង ៤ | ៣៥ |
| ១៦ | ទិដ្ឋភាពស្រុកស្រែពេលខែវស្សា | ៣៦ |
| ១៧ | ជំនឿរបស់ខ្មែរលើរូប "ទីងមោង" | ៣៧ |
| | **ចេតិតាស្ទៀន** | |
| ១៨ | បំបាត់ការឈឺចាប់ដោយខ្លួនឯង | ៣៩ |
| | **ព័ត៌មាន** | |
| ១៩ | តើអ្នកគ្រូ លោកគ្រូដឹងដែរឬទេ... | ៤២ |
| ២០ | បុគ្គលិកអប់រំនៅមន្ទីរអប់រំខេត្ត/ក្រុង... | ៤៤ |
| ២១ | ស្ថិតិសពខែតុលា-វិច្ឆិកា-ធ្នូ ឆ្នាំ២០០៥ | ៤៥ |
| ២២ | វេទិកាស្ត្រី : សិទ្ធិបន្តពូជ | ៥១ |


**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

ភ្នំពេញ : ០១២ ៨៩៧ ១៧៧, កំពត : ០១២ ៨៥៦ ៧២២, ក្រុងព្រះសីហនុ : ០១២ ៦៩៩ ៥៦០

សៀមរាប : ០៦៣ ៧៦០ ២១៣ / ០១១ ៨៩៧ ០៥៦ / ០១២ ៦៧៥ ៦៤០

# វិចារណកថា

មនុស្សលោកត្រូវការធម្មជាតិ ដើម្បីរស់។

កាលពីសិបលានឆ្នាំកន្លងមក ប្រជាជននៃពិភពលោកមានចំនួនតិចតួច និងរស់នៅរាយប៉ាយលើផែនដី។ បច្ចុប្បន្ននេះ ចំនួនប្រជាជនកើនឡើងច្រើនសំបើមណាស់ ហើយវិទ្យាសាស្ត្រ និងបច្ចេកទេស ក៏បានរីកចំរើន ទុកស្លាកស្នាមយ៉ាងជ្រៅៗនៅលើផែនដី។ តែបើយើងបំផ្លិចបំផ្លាញបរិស្ថានធម្មជាតិ បើយើងមិនព្រមសំរុះសំរួល ផ្ដល់ការគោរពដល់សិទ្ធិរបស់ធម្មជាតិទេនោះ គឺយើងប្រថុយប្រថាននឹងការធ្វើអោយធម្មជាតិខូចខាតធ្ងន់ធ្ងរ និងអាចឈានដល់ការធ្វើអោយវិនាសជារៀងរហូតទៀតផង។ ដូច្នេះហើយ វាជាការចាំបាច់ណាស់ដែលយើងត្រូវតែរកមធ្យោបាយយ៉ាងណា ដើម្បីរស់នៅអោយបានសុខដុមជាមួយធម្មជាតិ។

អង្គការអប់រំវិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ(យូណេស្កូ) បានចូលរួមបង្កើតឋានីយជីវមណ្ឌល[១] ដែលជាកន្លែងមានឯកសិទ្ធិសំរាប់មនុស្ស និងធម្មជាតិ។ នោះពុំមែនជាកន្លែងមួយដាច់ដោយឡែកទេ តែជាកន្លែងស្រាវជ្រាវពិសោធរកមធ្យោបាយដ៏គាប់ប្រសើរដែលមនុស្ស និងធម្មជាតិអាចរួមរស់ជាមួយគ្នាបានប្រកបដោយនិរន្តរភាព។ មេរៀនទាំងឡាយដែលដកពិសោធន៍បានមកពីឋានីយជីវមណ្ឌល មានតំលៃបំផុតសំរាប់ផ្នែកផ្សេងៗទៀតនៃភពផែនដី ដើម្បីអនាគតនៃផែនដី។

មកដល់បច្ចុប្បន្ននេះ យើងមានឋានីយជីវមណ្ឌលគ្រប់ប្រភេទចំនួន ៤៨២ ស្ថិតនៅគ្រប់តំបន់នៃពិភពលោកក្នុង ១០២ប្រទេសនៃទ្វីបនានា។ នៅកម្ពុជាក៏បានបង្កើត និងកំណត់តំបន់ការពារធម្មជាតិ តាមព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣* ដែលរួមមាន ÷

- ឧទ្យានជាតិ : ៧កន្លែង
- ដែនជំរកសត្វព្រៃ : ១០កន្លែង
- តំបន់ការពារទេសភាព : ៣កន្លែង
- តំបន់ប្រើប្រាស់ច្រើនយ៉ាង : ៣កន្លែង

ក្នុងចំណោមតំបន់ការពារធម្មជាតិទាំង២៣កន្លែងនេះ តំបន់ទន្លេសាបបានចូលជាឋានីយជីវមណ្ឌលនៃពិភពលោក កាលពីឆ្នាំ១៩៩៧។

យើងដឹងហើយថា កន្លងមកក៏ដូចតទៅអនាគត ធម្មជាតិនៅអាចជួយធានាដល់ការរស់រានរបស់មនុស្ស ដោយខានមិនបាន។ យើងក៏ដឹងផងដែរថា ធម្មជាតិក៏ត្រូវការមនុស្សដែរ ដើម្បីថែរក្សាអត្ថិភាពរបស់ខ្លួន។ បញ្ហានេះតំរូវអោយរកដំណោះស្រាយតុល្យភាពអោយបានយ៉ាងឆាប់បំផុតរវាងការអភិរក្សបរិស្ថានធម្មជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ច។ បើយើងចង់អោយផែនដីនៅតែជាផែនដីដូចដើមសំរាប់មនុស្សជំនាន់ក្រោយៗជារៀងរហូត នោះគ្មានជំរើសណាក្រៅពីការធានារបៀបរបបរស់នៅរបស់យើង កុំអោយទៅបំផ្លាញដល់ធនធានធម្មជាតិដែលនៅជុំវិញខ្លួនយើងនោះឡើយ ៕

**គណៈកម្មាធិការនាយក**

(១) Réserves de biophères : តំបន់ជីវមណ្ឌលរក្សាទុកសំរាប់ថែរក្សា និងការពារពពួកសត្វ និងពពួករុក្ខជាតិដុះដាល និងរស់នៅបានតទៅ។

* សូមអាន "តំបន់ការពារធម្មជាតិ" នៅទំព័រ៤២

# ជំហានសារវន្តដែលអ្នកគ្រប់គ្រងម្នាក់ៗត្រូវដឹង

## ទំរង់ការសំរាប់ធ្វើសេចក្ដីសំរេច(*)

ចំណុចសំខាន់ៗសំរាប់ធ្វើសេចក្ដីសំរេចមាន ៩ ដែលគេយកអក្សរឡាតាំង ៩ តួសំរាប់កត់សំគាល់នោះគឺ D-E-C-I-S-I-0-N-S ហើយ ដើម្បីងាយស្រួលចាំនោះ យើងផ្សំអក្សរនោះបង្កើតបានជាបញ្ញត្តិមួយ : "DECISIONS" មានន័យថា សេចក្ដីសំរេច ។ រីឯជំហាននៃការធ្វើសេចក្ដីសំរេចនោះគឺ :

១- **Define** desired outcome កំណត់លទ្ធផលដែលចង់បាន

២- **Establish** decision criteria កសាងលក្ខណៈវិនិច្ឆ័យនៃសេចក្ដីសំរេច

៣- **Consider** the alternative solutions ពិនិត្យដំណោះស្រាយដែលមានផ្លូវផ្សេងទៀត

៤- **Investigate** get all possible facts ស្រាវជ្រាវរាល់ហេតុការណ៍ដែលអាចនឹងកើតឡើងនាពេលខាងមុខ

៥- **Settle** on top three choices សំរាំងយកការជ្រើសរើស ៣

៦- **Initiate** a comparison of the choice ផ្ដួចផ្ដើមធ្វើការប្រៀបធៀបជំរើស

៧- **Opt** for the best choice ជ្រើសយកជំរើសដែលល្អជាងគេ

៨- **Notify** those involved with decisiveness ប្រកាសពីអ្វីដែលបានអារកាត់រួចហើយ

៩- **See** that decision is fully implemented ពិនិត្យមើលថាតើសេចក្ដីសំរេចនេះអាចអនុវត្តបានយ៉ាងពេញលេញ(១) ឬទេ?

ប្រែសំរួលដោយលោក កែច យ៉ារ

✍📖✍

កូនចៅយើងអោយតំលៃជីវិតរបស់យើង។ ប្រសិនបើពួកយើងបានអប់រំគេល្អ គេនឹងរីករាយនៅពេលគេចាស់។ ផ្ទុយទៅវិញ ពួកគេត្រូវបានទទួលការអប់រំមិនល្អ ពួកគេនឹងបង្កកង្វល់ និងអំពើអាស្រូវដល់យើង។ ដូចនេះ ពួកគេទុកដូចជាកញ្ចក់សំរាប់ឆ្លុះបញ្ចាំងចំណុចខ្វះខាត របស់យើងចំពោះអ្នកដទៃ។

ម៉ាការិនតូ

(*) The Art of Leadeship by George Manning and Kent Curtis (2003)

(១)សេចក្ដីសំរេចមានលក្ខណៈពេញលេញ : SMARTA (S = Soustainable, M = Mesurable, A = Altenuable, R = Reliable, T = Time-bond, A = Activated)




# អំពីពួកស្អូច

ក្នុងចំណោមប្រទេសអំបូរខ្មែរ-មន ដូចគ្នាគឺមានក្រុម ៣ ហៅថា ខ្មែរមួយ មនមួយ និងអំបូរខ្មែរភ្នំជាច្រើន។ ក្នុងចំនួនមនុស្សខ្មែរ-មន មានតែខ្មែរទេដែលមានមនុស្សច្រើនជាងគេ ហើយម្យ៉ាងទៀតមានតែខ្មែរទេ ដែលមានរដ្ឋមួយច្បាស់លាស់។ ឯមនវិញនៅជ្រកតែនឹងប្រទេសដទៃ ដូចជាប្រទេសភូមា និងថៃ។ កាលពីបុរាណ លោកមិនសរសេរថា ខ្មែរដូចយើងសរសេរក្នុងបច្ចុប្បន្ននេះទេ។ ក្នុងសិលាចារឹកជាខ្មែរ លោកសរសេរថា "ក្មេរ" ដូច្នេះវិញ។ អ្នកបាលីបានធ្វើពាក្យថា ខ្មែរទៅជាបាលីថា ខេមរៈ ប្រែថា "អ្នកមានសេចក្ដីក្សេមក្សាន្ត"។ ឈ្មោះដែលហៅថា កម ឬខម ដោយកើតមកពីការផ្សំសព្ទបញ្ចូលគ្នា :

ខម < ខ (ខ្មែរ) + ម (មន)

ការសិក្សាស្រាវជ្រាវអំពីបញ្ហាខ្មែរ-មននេះបានធ្វើឡើងជាលើកដំបូងនៅសតវត្សទី១៩ ហើយបានទទួលលទ្ធផលជាទីពេញចិត្តក្រៃលែង ហើយបានរកឃើញថា អំបូរខ្មែរ-មននេះ ពុំមែនមានតែខ្មែរ និងមន ប៉ុណ្ណោះទេ ប៉ុន្តែមានជាតិជាច្រើនទៀតដែលរស់នៅក្នុងប្រទេសនានានៃអាស៊ីភាគអាគ្នេយ៍ដូចជា :

- ជនជាតិសេណូយ (Senoi) សេម៉ាង (Semang) នៅសហព័ន្ធម៉ាឡេស៊ីយ៉ា
- ជនជាតិបលោង (Palaung) វ៉ា (Va) នៅប្រទេសភូមា
- ជនជាតិខ្មុ នៅប្រទេសឡាវ
- ជនជាតិព្នង ស្អៀង កួយ ព័រ ស្អូច នៅព្រះរាជាណាចក្រកម្ពុជា
- ជនជាតិចាម បាណា នៅប្រទេសវៀតណាម ។ល។

ក្នុងអំបូរខ្មែរ-មន ក្រៅពីខ្មែរ និងមនដែលយើងបានឃើញរួចមកហើយនៅមានកុលសម្ព័ន្ធជាច្រើនទៀតដែលអ្នកប្រាជ្ញបានចាត់ទុកថា ជាក្រុមរងនៃអំបូរខ្មែរ-មន (Sous-groupe Khmer-Mon)។

ក្នុងការសិក្សាអំពីក្រុមរងនៃអំបូរខ្មែរ-មន យើងសូមលើកយកក្រុមស្អូច (Sa auch) មកជំរាបជូនពីការរស់

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រង់តំបន់ជួរភ្នំដំរី (Chaîne de l'éléphant)។ ប្រជាពលរដ្ឋនៃក្រុមនេះមានប្រហែលជា ២០០នាក់[១] ។

## អំពីពួកស្អូច

ពួកស្អូចរស់នៅក្នុងខេត្តកំពត ពិសេសក្នុងតំបន់វាលរេញ។ ខ្មែរយើងបានហៅកុលសម្ព័ន្ធនេះថា "ស្អូច"។ ពួកនេះ ក៏បានហៅក្រុមខ្លួនថា ស្អូចដូច្នេះដែរ។ គេពុំដឹងអំពីដើមកំណើតនៃពួកកុលសម្ព័ន្ធនេះទេ។ ក្រុមនេះរកកលនឹងវិនាស ផុតពូជរួចម្តងទៅហើយ ព្រោះកាលពីឆ្នាំ១៨៤០ ពួកសៀមដែលបានលើកទ័ពចុះមកវាយស្រុកខ្មែរតាមផ្លូវហាទៀងនោះ បានចាប់ពួកស្អូចនាំជាឈ្លើយយកទៅស្រុកវា។ នៅតាមផ្លូវពួកស្អូចស្លាប់អស់ជាច្រើន ព្រោះសៀមធ្វើបាប។ ចំណែកពួកដែលនៅរស់វិញ ត្រូវបានស្តេចសៀមបញ្ជាឱ្យយកទៅនៅក្នុងភូមិមួយជិតក្រុងបាងកក។ តែពួកនេះចេះតែស្លាប់បន្តគ្នាម្តងម្នាក់ៗ រហូតទាល់តែនៅសល់មនុស្សពីរនាក់គត់។

ឃើញដូច្នេះ ស្តេចសៀមក៏អនុញ្ញាតអោយអ្នកទាំងពីរនេះត្រឡប់មកស្រុកកំណើតរបស់ខ្លួនវិញ។ មកដល់ស្រុកខ្មែរអ្នកទាំងពីរនេះបានប្រទះឃើញស្ត្រីក្នុងក្រុមខ្លួនបីនាក់ ដែលបានភៀសខ្លួនទៅរស់នៅជាមួយនឹងជាតិខ្មែរ ក៏បានរៀបការជាមួយគ្នាទៅ។ ដើម្បីកុំអោយកុលសម្ព័ន្ធស្អូចនេះស្លាប់បាត់ពូជ ស្តេចខ្មែរឱ្យពួកនេះរៀបការរវាងបងប្អូនបង្កើតរបស់ខ្លួនបាន[២] លើសពីនេះទៅទៀត ពួកស្អូចត្រូវបានស្តេចខ្មែរអនុញ្ញាតអោយជ្រើសរើសមេកោយរបស់ខ្លួនម្នាក់មានងារជា "ឧកញ៉ាគីរី" ដែលមានបុណ្យសក្តិប៉ុនគ្នានឹងចៅហ្វាយ ខេត្តកំពត។

ការរស់នៅរបស់ពួកស្អូច មានការប្រហាក់ប្រហែលគ្នាច្រើននឹងជីវភាពរបស់ជនជាតិខ្មែរយើង។ តទៅនេះយើងនឹងជំរាបអំពីការរស់នៅ និងទំនៀមទំលាប់ខ្លះរបស់ពួកស្អូច។

### អំពីការកើតកូន

បើកាលណាមានស្ត្រីឈឺពោះហៀបនឹងកើតកូន គេទៅរកឆ្មបដែលពួកស្អូចហៅថា "ឧនពាង" អោយមកជួយដោយពុំមានរៀបពិធីអ្វីទេ។ ឧនពាង យកដៃទៅអង្អែលពោះមាតា ហើយជួយតម្រែតម្រង់ និងរុញច្រានអោយទារកប្រសូតចេញមកបានដោយស្រួល។ គាត់ពុំបានប្រើមន្តអាគមអ្វីសំរាប់ស្តោះផ្លុំទេ។ លុះទារកប្រសូតចេញមកហើយ គាត់ក៏ចងទងផ្ចិត រួចកាត់នឹងបន្ទះឫស្សីពកដែលមានមុខមុតដូចកាំបិតកោរ។ តមកឧនពាងយកទារកទៅផ្ងូតទឹក ដុសលាងអោយស្អាតរួចយកទៅដាក់ផ្តេកជិតមាតារបស់វា។ ចុងទងផ្ចិតកាលណាជ្រុះហើយ គេយកវាទៅបោះចោលក្នុងទន្លេ ឬក៏យកទៅដុតចោល។ គេហាមមិនអោយយកទៅកប់ទេ ចំណែកសុកវិញ ក៏គេត្រូវយកទៅដុតចោលដែរ ព្រោះទំនៀមទំលាប់ពីបុរាណតម្រូវអោយធ្វើដូច្នេះ។

រង្វាន់ដែលគេត្រូវជូនទៅឆ្មប ឬឧនពាង មានកំណាត់សពីរហត្ថ ស្រាមួយកំប៉ុក[៣] ទៀនសុទ្ធ៥ដើម និងធូបក្រអូប៥ដើម។

គេមិនទាន់កោរសក់ទារកដែលទើបនឹងកើតទេ។ ការដាក់ឈ្មោះអោយទារកក៏ធ្វើឡើងដោយគ្មានពិធីអ្វីដែរ។

(១) សៀវភៅអរិយធម៌ខ្មែរ -មន របស់លោកកែប រ៉េអ៊ី ឆ្នាំ១៩៧១
(២) CF-les Sa auch par Adhémard Leclère. Saigon 1910
(៣) ដបតូចខ្ចី ធ្វើពីឬ ស្រាប់ដូចពាង រឺខូច

មាតាបំបៅទារករហូតដល់មានផ្ទៃពោះកូនមួយទៀតទើបឈប់ ។ ប្រសិនបើមាតាពុំមានកូនទៀតទេ ការបំបៅនេះ នៅតែបន្តរហូតដល់កូនក្មេងនោះឈប់លែងបៅខ្លួនវា ។

## ពិធីរៀបមង្គលការ

កាលណាមានក្មេងប្រុសណាម្នាក់ស្រឡាញ់ចង់បានយុវនារីមកធ្វើជាប្រពន្ធរបស់ខ្លួន យុវបុរសនោះត្រូវយកឆ្នាំងថ្មី ឬបំពង់ឫស្សីទៅដងទឹកយកទៅដាក់ក្នុងផ្ទះរបស់នាងនោះ ។ ប្រសិនបើនាងនោះយល់ព្រមប្រើប្រាស់ទឹកនោះបានសេចក្តីថា នាងព្រមទទួលបុរសនោះជាគូស្រករបស់នាងហើយ ។ ប្រសិនបើនាងក្រមុំពុំព្រមប្រើទឹកនោះវិញទេ យុវបុរសត្រូវយកទឹករបស់ខ្លួន ហើយទៅជ្រើសរើសរកនារីផ្សេងទៀតជាអនាគតភរិយា ។

ក្នុងករណីដែលយុវនារីយល់ព្រមប្រើប្រាស់ទឹករបស់យុវជន គេក៏នាំនាងទៅផ្ទះរបស់ឪពុកម្តាយខាងប្រុស ហើយរៀបចំពិធីជប់លៀងសែនព្រេន ដើម្បីប្រកាសប្រាប់ដល់ញាតិមិត្ត និងខ្មោចដូនតា ។

ការប្រើប្រាស់ទឹក ដើម្បីស្តីដណ្តឹងបែបនេះនាំអោយយើងនឹកទៅដល់ចម្រៀងមួយដែលខ្មែរយើងនិយមច្រៀងក្នុងពិធីរៀបមង្គលការដែលមានឈ្មោះថា បទ "ទឹកជប់ ឬទឹកទប់" ហើយមានទំនុកដូចតទៅនេះ :

| | | | |
|---|---|---|---|
| ទឹកអើយទឹកជប់ | ទឹកនៅក្នុងម្ជប់ | ទឹកជប់រងថ្លា | |
| ទឹកពីធម្មជាតិ | ជ្រួតជ្រាបកាយា | ទឹកជប់រងថ្លា | ក្នុងជ្រោះជ្រាលជ្រៅ ។ |
| ទឹកអើយទឹកជប់ | ទឹកនៅក្នុងម្ជប់ | សោឡសឆ្នាំណា | |
| រង់ចាំកំណត់ | ជប់ប្រាំមាសា | ជោគជ័យពេលា | រាសីបានហើយ ។ |
| ទឹកអើយទឹកជប់ | ទឹកនៅក្នុងម្ជប់ | ជោគជាំធរណី | |
| រដូវដើមឆ្នាំ | ភ្លៀងលិចទួលទី | ជោគជាំធរណី | ឥតទរណាហ៊ានបើក ។ |
| ផ្ការលាន់ឯជើង | ឆ្លើយឡើងកក្រើក | ឥតទរណាហ៊ានបើក | |
| ទំលាយទឹកទៅ | មានតែអ្នកមហា | ហើយនិងអ្នកផ្លូវ | លោកកែតម្រូវ សូមទំលាយទឹកទប់ ។ |

សព្វថ្ងៃនេះ ពួកស្ទួចបានបោះបង់ទំនៀមទំលាប់របស់ខ្លួនចោលបន្តិចម្តងៗ ហើយចម្លងយកទំនៀមទំលាប់ខ្មែរយើងទៅប្រើប្រាស់ស្ទើរតែទាំងអស់ ជាពិសេសក្នុងពិធីមង្គលការកូនប្រុសស្រីនេះឯង ។

ប្រសិនបើមានមនុស្សស្លាប់ ពួកស្ទួចនិយមយកសពទៅកប់ ។ ពួកនេះមិនដែលយកសពទៅបូជាសោះឡើយ ។ ឯផ្នូរខ្មោចវិញ ក៏គេពុំរៀបចំឱ្យបានល្អទេ ព្រោះគេពុំដែលបានទៅធ្វើពិធីគោរពបូជានៅទីនោះឡើយ ។

ស្រីស្ទួចមានការខ្មាសអៀនច្រើនណាស់ ។ ប្រសិនបើមានមនុស្សចម្លែកណាម្នាក់ចូលទៅក្នុងភូមិរបស់ខ្លួន ស្រីៗរត់ទៅពួនក្នុងផ្ទះ ហើយលបមើលមកក្រៅតាមប្រហោងជញ្ជាំង ។ ពួកស្ទួចពុំសូវមានវិវាទឈ្លោះប្រកែកគ្នាទេ ។ ពួកនេះទៀងត្រង់ណាស់ មិនចេះភូតកុហក មិនចេះលួច ។ ឯការសហាយស្មន់ ឬផិតប្តីប្រពន្ធក៏ពុំដែលកើតមានដែរ ៕

លោក ចែម ផាន បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជសាស្ត្រ និងរដ្ឋបាល
សាស្ត្រាចារ្យប្រវត្តិវិទ្យា និងអធិការបឋមសិក្សាជំនាន់ទី១ (១៩៩៤-៩៥)

# ទំនៀមទំលាប់ និងប្រពៃណីខ្មែរ ស្តីពីការអប់រំមារយាទសម្បត្តិ

(តពីលេខ២៤)

## ស្បែកជើង

គេនិយមប្រើទ្រនាប់ជើងដែលហៅថា ស្បែកជើង ដើម្បីការពារបាតជើងកុំអោយប៉ះទង្គិច ឬមុត និងការពារកំដៅ ឬភាពត្រជាក់ផង ជារបៀបតែងខ្លួនតាមអឺរ៉ុប។ ចំណែកខាងគារវកិច្ចរបស់គ្រហស្ថអ្នកកាន់ព្រះពុទ្ធសាសនាវិញ ការពាក់ស្បែកជើងចូលវត្តមានការទាស់ខុស ជាច្រើនប្រការ ÷

១-ព្រះសង្ឃដែលគ្មានពាក់ស្បែកជើង មិនត្រូវនិយាយស្តីជាមួយនឹងគ្រហស្ថដែលពាក់ស្បែកជើងទេ។ បើពាក់ដូចគ្នាមិនជាការទាស់ខុសទេ។

២-គ្រហស្ថមិនត្រូវពាក់ស្បែកជើងឡើងកុដិលោកសង្ឃឬឡើងព្រះវិហារ ព្រះចេតិយទេ ត្រូវដោះទុកនៅកាំជណ្តើរខាងក្រោម ទើបរួចទោសកំហុស។

ចំណែកព្រះវិហារ និងព្រះចេតិយ ត្រូវយើងជាអ្នកចេះអប់រំថ្វាយបង្គំព្រះពុទ្ធ ចេះហាមខ្លួនយើងផង ហាមអ្នកដទៃផង ដែលពុំបានដឹងជាក់ក្នុងគារវកិច្ចថា : "កុំអោយពាក់ស្បែកជើងឡើង". ចុះបើមានជនបរទេសដែលជាអ្នកមិនកាន់ព្រះពុទ្ធសាសនានោះ អ្នកចាំព្រះវិហារ ទោះព្រះសង្ឃក្តី គ្រហស្ថក្តី គប្បីប្រាប់ពន្យល់អោយដឹងផងថា "ត្រូវតែដោះស្បែកជើងទើបចូលបាន" យ៉ាងនេះហើយ ទើបសមរម្យនឹងឈ្មោះដែលហៅថា អ្នកកាន់ព្រះពុទ្ធសាសនា។

តួយ៉ាងដូចជានៅវត្តព្រះកែវមរកតរាជវារាម ក្រុងភ្នំពេញសព្វថ្ងៃនេះ មានជនបរទេសចូលមកមើលគ្មានលស់ថ្ងៃណាមួយសោះឡើយ តែទៅដល់ព្រះវិហារពួកមគ្គុទេសក៍ (អ្នកនាំផ្លូវ) ព្រះរាជវាំងពន្យល់អោយដោះស្បែកជើងសិន ទើបអោយឡើងចូលមើល។ មិនតែប៉ុណ្ណោះ មានទាំងបំរាមបិទនៅសន្លឹកទ្វារទៀត ប្រាប់អោយដោះស្បែកជើង និងមួក។ បញ្ញត្តិនេះមិនមែនគិតតែលើអ្នកតូចទេ ទោះជាអ្នកធំក៏សុំអោយដោះស្បែកជើងជាដរាប។ សូម្បីតែព្រះករុណាជាម្ចាស់ផែនដី ព្រះអង្គក៏ទ្រង់បំពេញគារវកិច្ចបានបរិបូរណ៍ ព្រះអង្គទ្រង់ដោះព្រះសុព័ណបាទទុកសិន បានស្តេចយាងចូលព្រះវិហារ។

ការពោលរាប់រៀបយ៉ាងនេះ ហាក់ដូចជាមើលងាយលោក-អ្នកពេក។ ប៉ុន្តែយើងឃើញមានក្មេងកំលោះក្រមុំ និងជំទង់មួយចំនួនពាក់ស្បែកជើងឡើងព្រះវិហារ ព្រះចេតិយ ប្រហែលពុំដឹងវិន័យក្នុងគារវកិច្ចដែលយើងរាល់គ្នាត្រូវសំដែងសេចក្តីគោរពចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ ដូច្នេះ ដំណើរទៅវត្តជាដំណើរទៅរកបុណ្យ មិនប្រមូលយកបុណ្យត្រឡប់ទៅជាអោបក្រសោបរវែចយកបាបមកផ្ទះវិញ ដោយទោសខុសក្នុងគារវកិច្ចនោះឡើយ។ នេះជាការគួរអោយស្តាយណាស់សម្រាប់យើងជាអ្នកថ្វាយខ្លួនក្នុងព្រះពុទ្ធសាសនា។

**ស្បែកជើង មានច្រើនប្រភេទ ÷**

១-ស្បែកជើងឃ្លុប គឺស្បែកជើងកខ្លី ស្បែកជើងកវែង នេះបើយើងរៀបខ្លួនត្រឹមត្រូវ គឺស្លៀកសំពត់ ពាក់អាវកុត ឬអាវចងក្រវ៉ាត់ ស្បែកជើង ស្រោមជើង ឬតែងខ្លួនរបៀបអឺរ៉ុប ហើយបើទៅផ្ទះគ្រហស្ថដូចគ្នានោះ យើងត្រូវពាក់បានរហូតដល់ទីកន្លែងដែលគេទទួលយើង មិនត្រូវដោះទុកនៅខាងក្រៅទេ កុំគិតខ្លាចថា ព្រោះផ្ទះអ្នកធំ ឬផ្ទះចៅហ្វាយនាយអោយសោះ លោកអ្នកធំលោកពុំប្រកាន់ទេ លោកជ្រាបរបៀបសព្វគ្រប់អស់ហើយ បើដោះស្បែកជើងនេះចេញវិញ ទៅជាជំទាស់នឹងទម្លាប់អារ្យធម៌អឺរ៉ុបទៅវិញ ។

២-ស្បែកជើងមិនឃ្លុបជិតត្រូវរាប់យកស្បែកជើងផ្ទាត់គ្រប់បែបយ៉ាង និងស្បែកជើងឈើ ។ បើពាក់ស្បែកជើងផ្ទាត់ ឬស្បែកជើងឈើទៅវត្ត ត្រូវដោះទុកកាំជណ្តើរក្រោមជាដរាបនៅព្រះវិហារក៏ដោយ នៅកុដិលោកក៏ដោយ ។ តែបើទៅផ្ទះគ្រហស្ថដូចគ្នាវិញ ស្បែកជើងឈើត្រូវទុកនៅកាំជណ្តើរក្រោមបង្អស់ ។ ឯស្បែកជើងផ្ទាត់ពាក់ឡើងទៅលើផ្ទះគេបានតែត្រឹមមាត់ទ្វារមុខ ។

៣-ស្បែកជើងសង្រែកពាក់បានតែដើរលេងទៅវត្ត-ទៅធ្វើការងារ ព្រោះបើមានការត្រូវដោះចេញ យើងនឹងដោះបានដោយងាយ ។ តែបើយើងពាក់ទៅរកអ្នកធំ មានតាល់ព្រះមហាក្សត្រក្តី ក្សត្រធំៗក្តី រដ្ឋមន្ត្រីក្តី នេះមិនបានជាដាច់ខាត ។ សូម្បីតែទៅទទួលលៀងក្រយាហារក្នុងឱកាសផ្សេងៗនោះ ស្បែកជើងសង្រែកក៏មិនសមរម្យនឹងពាក់ទៅទេ ។ ស្បែកជើងសង្រែកទុកដូចជាស្បែកជើងផ្ទាត់ដែរ ។ ស្បែកជើងសង្រែកមិនទុកជាគ្រឿងប្រដាប់មួយដែលប្រើប្រាស់បានដូចជាស្បែកជើងឃ្លុបជិតជើងទេ ។

## មួក និងឆ័ត្រ

ពួកពុទ្ធមាមកៈ មិនត្រូវពាក់មួក ឬបាំងឆ័ត្រដើរកាត់វត្តឡើយ សូម្បីតែដើរកាត់មុខវត្ត ក៏ត្រូវដោះមួកពីក្បាលចេញ ឬបិទឆ័ត្រ ដើរអោយផុតពីវត្តទៅសិន ចាំពាក់-បាំងតទៅទៀត ។ អ្នកដែលគេកាន់គារវកិច្ចយ៉ាងមាំទាំ គេតែងលើកដៃថ្វាយបង្គំព្រះពុទ្ធអង្គថែមទៀតផង កាលណាគេដើរទៅដល់មុខព្រះវិហារ ។ តែប្រសិនជាដើរទៅប្រទះនឹងភ្លៀងបង្អុរមកនោះ គប្បីបាំងឆ័ត្រទៅចុះ ឯមួកហាមដាច់ខាតមិនត្រូវពាក់ដើរចូលក្នុងវត្ត ឬកាត់មុខវត្តអោយសោះ មិនថាពេលណាជាពេលណាឡើយ ។ មិនតែប៉ុណ្ណោះទេ ដូចជាទទូរសំពត់ ឬជួតក្បាល ក៏ត្រូវមានកិច្ចគារវវត្តដូចគ្នានឹងពាក់មួកដែរ ។

## គ្រឿងអលង្ការ និងគ្រឿងក្រអូប

ស្រីៗស្រឡាញ់សំលៀកបំពាក់ ស្រឡាញ់គ្រឿងអលង្ការ និងគ្រឿងក្រអូបជាទីបំផុតក៏ពិតមែនហើយ តែវេលាទៅវត្ត គួរគប្បីកុំតែងខ្លួនអោយហួសហេតុពេក ។ យើងបានអធិប្បាយហើយអំពីសំលៀកបំពាក់ទៅវត្ត ។ ទីនេះ ត្រូវបរិយាយអំពីគ្រឿងអលង្ការ និងគ្រឿងក្រអូបតទៅទៀត ។

ការរៀបចំខ្លួនប្រាណទៅវត្ត ហើយប្រដាប់ទៅដោយគ្រឿងអលង្ការ និងគ្រឿងក្រអូបនោះ មិនមែនហាមឃាត់ទេ តែត្រូវពាក់គ្រឿងមាសពេជ្រអោយល្មម កុំអោយច្រើនពេក ព្រោះការធ្លាប់ពាក់ទៅហើយ ក៏ពាក់ខ្លះទៅចុះដោយមិនធ្លាប់ខ្លួនទទេ ។ ឧបមាដូចខ្សែដៃយ៉ាងតូចមួយជុំម្ខាង និងចិញ្ចៀន១វង់សម្រាប់អ្នកនៅក្នុងវ័យកណ្តាល ។ បើ

ក្មេងអាចនឹងថែមខ្សែក ឬទំហូទៀតក៏មិនហួសប្រមាណដែរ។ តែចំពោះមនុស្សចាស់វិញ មិនគប្បីពាក់គ្រឿងអលង្ការច្រើនពេកទេ។

ឯទឹកអប់មិនត្រូវលាបច្រើនពេកអោយទាល់តែធ្ងើលគេឯងទេ គឺថាក្រអូបអស់មួយគុជិ ឬមួយសាលានោះ។ ម្យ៉ាងទៀត ក៏កុំប្រផ្ទូរពេក បបូរមាត់ក៏កុំអោយក្រហមពេកដែរ។ មូលសេចក្តីទៅ មិនត្រូវតែងខ្លួនអោយដូចដើរមើលបុណ្យង៉ាន ឬដើរលេងកំសាន្តធម្មតានោះទេ។ ការចូលវត្តត្រូវតែកាន់កិរិយាសុភាពជាដរាប។

## ១-សំលៀកបំពាក់សំរាប់ចូលរួមបុណ្យខ្មោច-កាន់ទុក្ខ

អ្នកដែលជាសាច់សាលោហិតរបស់សព ទោះញាតិជិតក្តី ឆ្ងាយក្តី គប្បីសម្តែងកិរិយាព្រម ទាំងវាចាឱ្យជាក់ថាខ្លួនមានសេចក្តីទុក្ខសោកដោយសេចក្តីព្រាត់ប្រាស់ញាតិសន្តានម្នាក់ក្នុងវេលានោះដែរ។

ពេលដែលសពតំកល់នៅលើផ្ទះ ត្រូវផ្លាស់សំពត់អាវដែលមានពណ៌ឆើតឆាយ (ក្រហម-លឿង-បៃតង)នោះចេញ គឺត្រូវស្លៀកសពាក់សវិញ ជាសញ្ញាសំគាល់អោយគេដឹងថា យើងជាអ្នកកាន់ទុក្ខ (នេះតាមបុរាណកាលរបស់ខ្មែរ)។ ចំណេរតមកការកាន់ទុក្ខនេះក៏ប្រែប្រួលបន្តិចម្តងៗ តាមបែបអារ្យធម៌នៃប្រទេសអឺរ៉ុប។ អ្នកខ្លះយល់ថា បើសពនោះត្រូវជាកូន-ប្អូន-ចៅ ក្មួយនោះ ពួកស្រីៗ គឺជីដូន ម្តាយ-បងស្រី-ម្តាយធំ-ម្តាយមីង គប្បីស្លៀកពាក់ខ្មៅ។ ចំណែកប្រុសៗវិញ គឺជីតា-ឪពុក-បងប្រុស-ឪពុកធំ-ឪពុកមា គប្បីស្លៀកខ្មៅពាក់ស (នៅផ្ទះក៏ដូចជាថ្ងៃហែសពទៅធ្វើឈាបនកិច្ចដែរ)។

ឯអ្នកដែលត្រូវជាប្អូន-ក្មួយ-ចៅរបស់សពទាំងប្រុសទាំងស្រី ត្រូវស្លៀកសពាក់សទាំងអស់។ ដល់អារ្យធម៌ប្រទេសអឺរ៉ុបចូលមក ប្រុសៗឈប់ប្រកាន់ថាបងឬប្អូន-កូនឬឪពុក-ចៅឬជីតា។ល។ តែកាលណាមានទុក្ខដោយដំណើរបាត់បង់សាច់សន្តានហើយ តែងតែប៉ាន់ដៃខ្មៅនៅដៃអាវខាងឆ្វេងទៀតជាសំគាល់។ តមកទៀត ប៉ាន់ដៃខ្មៅនេះក៏មានអ្នកខ្លះនៅប្រើ អ្នកខ្លះគ្រាន់តែយកសំពត់ខ្មៅប្រមាណជា២សង់ទីម៉ែត្រទទឹង ១០សង់ទីម៉ែត្របណ្តោយ មកខ្ទាស់ភ្ជាប់នឹងផ្នត់អាវបើកក។

សេចក្តីសង្ខេបនៃសំលៀកបំពាក់កាន់ទុក្ខបុរសនៅថ្ងៃរំលាយសព ឬបញ្ចុះសព ត្រូវស្លៀកពាក់សសុទ្ធប៉ាន់ដៃខ្មៅ និងក្រវាត់ខ្មៅ ស្បែកជើងសក៏បាន ខ្មៅក៏បាន។ ថ្ងៃតទៅ ប្រើខោអាវពណ៌ប្រផេះស្រគាំ តួរតែនៅចងក្រវាត់ខ្មៅដដែល ត្រូវកុំផ្លាស់ពណ៌ដទៃអោយសោះ លុះត្រាតែគ្រប់កំណត់វេលាដែលសន្មតទុកក្នុងចិត្តតាមរបៀបកាន់ទុក្ខដែលនឹងមានសម្តែងតទៅ ខាងក្រោយ។

ស្ត្រីក៏មានរបៀបរក្សាពណ៌សំពត់អាវអោយទៀងទាត់ដូចជាបុរសដែរ គ្រាន់តែគ្មានប៉ាន់ដៃ និងក្រវាត់កប៉ុណ្ណោះ។ គ្រឿងតែងខ្លួនអ្នកដែលពាក់កាន់ទុក្ខ (ខ្មៅក្តី សក្តី) គប្បីតែឈប់ពាក់គ្រឿងមាសពេជ្រជាដាច់ខាត លុះត្រាតែដល់ថ្ងៃលែងកាន់ទុក្ខនោះ។ បើកាន់ទុក្ខហើយ មិនត្រូវពាក់មាសពេជ្រ ហើយការលាបលនប្រេងម្សៅ និងបបូរមាត់ក្រហមក៏ត្រូវបង្អង់សិនដែរ។ (នៅមានត)

លោកស្រី ឈឹម ច័ន្ទតារា

ដកស្រង់ចេញពីសៀវភៅ "ទំនៀមទំលាប់ និងប្រពៃណីខ្មែរ" (អប់រំចរិយាសម្បត្តិ)របស់ ឧកញ៉ា ញ៉ុក ធូរ ឆ្នាំ១៩៥៩

# តើព្រះពុទ្ធសាសនាអាចនឹងសាបសូន្យមែនឬ?

មានមតិខ្លះបានវាយតំលៃថា នៅពេលអនាគតមិនឆ្ងាយប៉ុន្មាន ឥទ្ធិពលនៃពុទ្ធសាសនានឹងសាបរលាបរេចរិលរហូតរលាយសាបសូន្យដោយកត្តា ៣ យ៉ាង ៖

១-ការរីកចំរើននៃវិទ្យាសាស្ត្រ

២-ការវាយលុករបស់សាសនាដទៃ

៣-ពុទ្ធបរិស័ទ ពិសេសព្រះសង្ឃដែលជាសាវ័ករបស់ព្រះពុទ្ធផ្ទាល់ ចេះតែនាំគ្នាអនុវត្តងុយពីពុទ្ធឱវាទ។

បើយើងផ្ទៀងលើកត្តាទាំង ៣ ខាងលើ យើងពិតជាជឿដោយឥតប្រកែកថា ព្រះពុទ្ធសាសនាអាចនឹងសាបរលាបហើយឈានទៅរលាយសាបសូន្យពិតប្រាកដមែន ព្រោះ ៖

១. __**ការរីកចំរើននៃវិទ្យាសាស្ត្រ**__ : យើងបានឃើញហើយថា នៅពេលបច្ចុប្បន្ននេះ វិទ្យាសាស្ត្រមានការរីកចំរើនហួសពីការស្មាន។ អ្វីដែលពីអតីតកាល មនុស្សយើងមិនបានគិតឃើញថាមាន ឥឡូវនេះវិទ្យាសាស្ត្របានបកស្រាយអោយឃើញយ៉ាងច្បាស់ថាពិតជាមានមែន។ របកគំហើញរបស់វិទ្យាសាស្ត្រនេះមានចំណុចខ្លះបានទាត់ចោលទ្រឹស្តីព្រះពុទ្ធទាំងស្រុងទៀតផងដូចជា ៖

ក).ទ្រឹស្តីព្រះពុទ្ធ :

- មានស្ថានសួគ៌ (ស្ថានលើ) ជាស្ថានដែលទេវតា ព្រះឥន្ទ ព្រះព្រហ្មរស់នៅ។
- មានស្ថាននរក (ស្ថានក្រោម) ជាស្ថានដែលមានយមបាល យមរាជ ចាំធ្វើទារុណកម្មអ្នកដែលសាងអំពើបាបកាលនៅរស់។
- មនុស្សស្លាប់ នឹងចាប់ជាតិជាថ្មី ហើយទទួលផលកម្មពីជាតិមុន។
- ផែនដីគ្មានចលនា ព្រះអាទិត្យគោចរ។
- ...................................................

ខ).របកគំហើញរបស់វិទ្យាសាស្ត្រ : បានរកឃើញថា :

- គ្មានទេវតា ព្រះឥន្ទ ព្រះព្រហ្ម រស់នៅស្ថានលើទេ ជាក់ស្តែងយានអវកាសទៅចុះចតនៅស្ថានព្រះចន្ទ និងភពព្រះអង្គារជាញឹកញាប់ តែពុំមានជួបទេវតា ព្រះឥន្ទណាម្នាក់ទេ។
- នៅខាងក្រោម វិទ្យាសាស្ត្របានបង្ហាញថា ពុំមាននរក យមរាជយមបាលទេ គឺមានតែទំនាញផែនដីប៉ុណ្ណោះ ជាក់ស្តែងគេបុកអណ្តូងស្នប់ជំរៅ៤០ម៉ែត្រ ទៅ៥០ម៉ែត្រ បូមទឹកមកប្រើគ្រប់ស្រុក តែមិនដែលឃើញយមបាលណាមកតវ៉ាថា មនុស្សឈ្លានពានស្ថានក្រោមទេ។
- មនុស្សយើងកើតពីមេជីវិតបុរស បូកនឹងពងរដូវរបស់ស្ត្រី គឺមិនមែនកើតពីព្រលឹងអ្នកស្លាប់មកចាប់កំណើត ទេ។

- ផែនដីនិងព្រះអាទិត្យ វិទ្យាសាស្ត្របានបង្ហាញថា ផែនដីវិលជុំវិញខ្លួនឯង និងវិលជុំវិញព្រះអាទិត្យ ឯព្រះអាទិត្យពុំមានចលនាទេ។

សរុបសេចក្តីមកឃើញថា លទ្ធផលនៃការស្រាវជ្រាវតាមវិទ្យាសាស្ត្រ ធ្វើអោយលទ្ធិមនោនិយមកាន់តែថយឥទ្ធិពល ហើយទ្រឹស្តីព្រះពុទ្ធដែលមានទំនោរទៅខាងមនោនិយមដែរនោះ ក៏នឹងថយឥទ្ធិពលបណ្តើរៗលើសតិអារម្មណ៍មនុស្សលោកផងដែរ។

២. **ការទាក់ទាញរបស់សាសនាដទៃ** : ប្រទេសកម្ពុជាយើងបានប្រកាន់យកព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។ ប្រជាជនខ្មែរ៩៥% ជឿ និងគោរពសាសនាព្រះពុទ្ធ។ ប៉ុន្តែក្នុងរយៈពេលចុងក្រោយនេះ គេឃើញសាសនាដទៃ ពិសេសគ្រិស្តសាសនាកំពុងសកម្មអូសទាញប្រជាជនខ្មែរយើងគ្រប់ច្រកល្ហក គួរអោយព្រួយបារម្ភ។ ជាសច្ចភាព មនុស្សយើងបើមានជំនឿស៊ប់លើអ្វីមួយតែងចាត់ទុកអ្វីនោះ ល្អជាងគេ ពិសេសជាងគេ។ ដូចគ្នាដែរ ប្រជាជនខ្មែរពុំមានមើលឃើញសាសនាណាល្អវិសេសជាងព្រះពុទ្ធសាសនាឡើយ។ ប៉ុន្តែក្នុងកាលៈទេសៈដែលប្រជាជនខ្មែរកំពុងជួបកង្វះខាតខាងជីវភាពពួកបរិស័ទនៃគ្រិស្តសាសនា បានចុះផ្សព្វផ្សាយពីមេត្តាធម៌របស់ព្រះគ្រិស្ត ដោយបានជួយឧបត្ថម្ភគ្រឿងឧបភោគបរិភោគខ្លះៗក្នុងន័យអូសទាញយកជំនឿពីប្រជាជនលើគ្រិស្តសាសនារបស់គេ។ យើងបានដឹងរួចហើយថា ព្រះពុទ្ធសាសនាបានអប់រំបរិស័ទអោយជ្រះថ្លា បរិច្ចាគធនធានផ្ទាល់ខ្លួន ដើម្បីកសាងកុសល ផ្ទុយទៅវិញ គ្រិស្តសាសនាបានឃោសនាអោយមនុស្សជឿ និងស្មោះត្រង់នឹងព្រះគ្រិស្ត ដើម្បីអោយព្រះរបស់គេជួយវិញ សូម្បីតែ បាបដែលមនុស្សបានសាង ក៏ព្រះគេទទួលយកដែរ។

ស្ថិតក្នុងកាលៈទេសៈមួយដែលប្រជាជនខ្មែរកំពុងជួបប្រទះនូវបញ្ហាជីវភាពបែបនេះ សាសនាដទៃងាយនឹងអូសទាញណាស់ ដោយយកសម្ភារៈសំរាប់ជួយដោះស្រាយជីវភាពជាមធ្យោបាយ ហើយចង់រឺមិនចង់ប្រជាជនត្រូវតែដួលជំហរងាកទៅជឿសាសនាដទៃ ចោលពុទ្ធសាសនាជាមិនខាន។

៣. **ពុទ្ធបរិស័ទនាំគ្នាប្រព្រឹត្តខុសនឹងពុទ្ធឱវាទ** : យើងទាំងអស់គ្នាជាពុទ្ធសាសនិកជន សុទ្ធតែបានដឹងថា ឱវាទរបស់ព្រះពុទ្ធបានទូន្មានអ្នកជឿ អ្នកគោរពអោយសាងតែអំពើល្អ ពិសេសព្រះសង្ឃត្រូវគោរពវិន័យអោយបានល្អបំផុត ហើយលះបង់អោយអស់នូវអ្វីៗដែលនាំចិត្តអោយសៅហ្មង ភ្លើតភ្លើន ដើម្បីអោយមនុស្សទូទៅជឿទុកចិត្ត។ ប៉ុន្តែចាប់តាំងពីព្រះពុទ្ធចូលបរិនិព្វានទៅ ការប្រតិបត្តិតាមពុទ្ធឱវាទរបស់ពុទ្ធបរិស័ទកាន់តែរយីករយាកបន្តិចម្តងៗរហូតមកដល់បច្ចុប្បន្ន ការប្រតិបត្តិកាន់តែរយាលមែនទែន សូម្បីព្រះសង្ឃដែលយើងចាត់ទុកជាស្រែបុណ្យនោះ ក៏មានមួយចំនួនលែងប្រតិបត្តិតាមសង្ឃវិន័យ គឺហ៊ានលួចលាក់ស្ម័គ្រស្នេហាជាមួយស្រីញី មួយចំនួនទៀតប្រតិបត្តិតិចតួច បន្ទំភ្នែកមហាជនដូចជា ចូលចិត្តហ៊ឹហា ពាក់វ៉ែនតា ប្រើទូរស័ព្ទទំនើបៗ លួចមើលវីដេអូ រហូតហ៊ានលួចឆាន់ចំណីពេលយប់ទៀតផង...។ ទន្ទឹមនឹងការប្រព្រឹត្តខុសរបស់ពុទ្ធបរិស័ទ និងព្រះសង្ឃខ្លះនេះ ជនខិលខូចមួយចំនួនក៏បាននាំគ្នាជាន់ពន្លិចព្រះពុទ្ធសាសនាបន្ថែមទៀត ដោយលួចក្លែងភេទជាសង្ឃដើររកលុយកាក់យកមកបំពេញតណ្ហាពាលាផ្សេងៗ ធ្វើអោយព្រះពុទ្ធសាសនាអាប់ឱន មហាជនកាន់តែអស់ជំនឿ។

ឆ្លងតាមបំណកស្រាយខាងលើ យើងអាចវាយតំលៃបានថា បើកត្តាទាំង ៣ ខាងលើចេះតែរីកចំរើន លទ្ធិពុទ្ធនិយមនឹងកាន់តែថយឥទ្ធិពល ហើយយូរៗទៅ ទ្រឹស្តីព្រះពុទ្ធពិតជារលាយសាបសូន្យមិនខាន។

## តើពុទ្ធសាសនិកជនខ្មែរមានការពិចារណាលើបញ្ហានេះបែបណា?

បើយើងទាំងអស់គ្នាមិនពិចារណាអោយបានស៊ីជំរៅ ហើយព្រមទទួលយកមតិខាងដើមទុកជាមតិត្រឹមត្រូវនោះ ជំនឿរបស់យើងលើព្រះពុទ្ធសាសនាប្រាកដជាស្រុតចុះជាមិនខាន ប៉ុន្តែបើយើងវិភាគអោយដិតដល់ យើងនឹងឃើញថា មតិខាងលើគ្រាន់តែជាទស្សនៈរបស់មនុស្សក្រុមតូចដែលចូលចិត្តយកបញ្ហាមួយផ្នែកតូចមកវាយតំលៃរួម។ តាមពិត ព្រះពុទ្ធសាសនាបានចាក់ឫសយ៉ាងជ្រៅ រឹងមាំណាស់ក្នុងសតិអារម្មណ៍ប្រជាជនខ្មែរយើង មិនងាយនឹងមានមូលហេតុអ្វីមកកំទេចរំលាយបានស្រួលៗនោះទេ។ ការរីកចំរើនរបស់វិទ្យាសាស្រ្ត កន្លែងខ្លះមើលទៅហាក់ដូចជាផ្ទុយនឹងទ្រឹស្តីព្រះពុទ្ធ ប៉ុន្តែការពិតគឺជួយបកស្រាយអោយយើងមើលឃើញនូវសិល្បវិធីអប់រំរបស់ព្រះពុទ្ធទៅវិញ ឧទាហរណ៍: ទ្រឹស្តីព្រះពុទ្ធពោលថា មានស្ថានសួគ៌ ស្ថាននរក មានទេវតា ព្រះឥន្ទ ព្រះព្រហ្ម យមរាជ។ល។ ឯវិទ្យាសាស្រ្តថា អត់ ត្រង់ចំណុចនេះ ព្រះពុទ្ធក៏ទ្រង់ឈ្វេងយល់ថា អត់ដែរ។ ប៉ុន្តែព្រះអង្គយល់ថា នៅក្នុងសង្គមមនុស្សមានវណ្ណៈខ្ពស់ (ទេវតា ព្រះឥន្ទ) រស់នៅក្នុងភាពសុខស្រួល (ស្ថានសួគ៌) និងវណ្ណៈទាប កំសត់ ទុរគត (ប្រេត នរក) និងវណ្ណៈមួយទៀតមិនក្រពេក មិនមានពេក គឺមធ្យមរស់ស្ថានកណ្តាល។ ដើម្បីមនុស្សទូទៅងាយយល់ពីវណ្ណៈនេះ ព្រះពុទ្ធបានប្រឌិតអោយមានស្ថានសួគ៌ ស្ថាននរក ស្ថានកណ្តាល មានទេវតា ព្រះឥន្ទ ព្រះព្រហ្ម ប្រេត មនុស្សធម្មតាមកប្រៀបធៀបវិញ។ ចំពោះពាក្យយមបាល យមរាជ នៅស្ថាននរក គឺជាវិធីសាស្រ្តអប់រំមនុស្សកុំអោយប្រព្រឹត្តអំពើអាក្រក់ អំពើបាប ដោយអាងថា ខ្លួនមានអំណាច ខ្លាំងពូកែ មិនអាចនរណាហ៊ានប្រឆាំង ប៉ុន្តែប្រយ័ត្នដល់ពេលស្លាប់ គ្មានអ្នកណាហ៊ានប្រកែកនឹងយមបាលទេ ប្រព្រឹត្តអំពើអាក្រក់ អំពើបាបប៉ុណ្ណា ត្រូវតែទទួលទោសទណ្ឌកម្មក៏វិតនោះ។ ដោយសារវិធីសាស្រ្តដ៏ល្អ នេះ មនុស្សយើងមិនសូវហ៊ានសាងបាបទេ។

ចំពោះបញ្ហាការវាយលុករបស់សាសនាដទៃ គឺជាបញ្ហាមិនទាន់អោយព្រួយបារម្ភពេកទេ ព្រោះព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ហើយសតិអារម្មណ៍ប្រជាជនខ្មែរ ក៏មានជំនឿស៊ប់លើការអប់រំរបស់សាសនាព្រះពុទ្ធតាំងពីយូរលង់មកហើយដែរ។ ចំណែកបញ្ហាការប្រតិបត្តិខុសរបស់ពុទ្ធបរិស័ទ ក៏ជាបញ្ហាបន្ទាប់បន្សំដែរ ព្រោះជាការប្រព្រឹត្តខុសទាំងច្បាប់ពុទ្ធចក្រ ទាំងច្បាប់អាណាចក្រ។ ដូចនេះ ពួកដើរខុសផ្លូវមួយចំនួនតូចបំផុតនេះ ពុំមានឥទ្ធិពលអ្វីធ្វើអោយព្រះពុទ្ធសាសនារលាយសាបសូន្យបានទេ។

ជាមតិវិភាគចុងក្រោយ យើងឃើញថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ មានចែងក្នុងបាវចនាជាតិច្បាស់លាស់ (ជាតិ សាសនា ព្រះមហាក្សត្រ) ហើយមានការអប់រំល្អទាំងខ្លឹមសារ ល្អទាំងវិធីអប់រំ ញុាំងអោយប្រជាជនខ្មែរ៩៥% មានជំនឿ។ ដោយសារខ្មែរយើងកាន់ព្រះពុទ្ធសាសនានេះហើយ ទើបខ្មែរយើងមានជំនឿលើបុណ្យ បាប ហើយនាំគ្នាសាងបុណ្យបន្ថយបាប។ បើប្រជាជនទាំងអស់ប្រកាន់ខ្ជាប់ត្រឹមសីល ៥ (បាណាតិបា អទិន្នាទាន កាមេ មុសា សុរា) អោយបានខ្ជាប់ខ្ជួននោះ ជាតិសាសន៍ខ្មែរពិតជារស់នៅបានសុខសប្បាយពេកហើយ។ បើសាសនាព្រះពុទ្ធកំពុងមានឥទ្ធិពលផ្នែកជំនឿលើប្រជាជនខ្មែរដូចបច្ចុប្បន្ននេះ ទោះបីវិទ្យាសាស្រ្តរីកចំរើនក៏វិតណាក៏ដោយ ទោះបីសាសនាដទៃវាយលុកប៉ុណ្ណាក៏ដោយ និងទោះបីអ្នកខ្លះប្រតិបត្តិខុសពីពុទ្ធឱវាទក៏ដោយ ក៏ព្រះពុទ្ធសាសនាមិនអាចសាបសូន្យពីកម្ពុជាដែរ៕

លោក ឆាត់ សាំ

๛📖๛



# ទំនាក់ទំនងរវាងវិន័យ និងសមត្ថភាពគ្រូ

នៅពេលសិស្សមានអាកប្បកិរិយាមិនសមរម្យ គ្រូត្រូវតែយកសមត្ថភាពដ៏ជាក់លាក់ទាំងអស់របស់ខ្លួនមកប្រើធ្វើជាមធ្យោបាយសំរាប់ដោះស្រាយស្ថានភាពនោះ ។ ធម្មជាតិនៃសមត្ថភាពនឹងត្រូវយកមកប្រើដូចម្ដេចខ្លះ ដែលអាចមានឥទ្ធិពលជាគំរូទៅដល់អាកប្បកិរិយាសិស្សក្នុងថ្នាក់រៀនអោយមានវិន័យឡើងវិញ ។

លោក Raven (1959) ជនជាតិបារាំង បានកំណត់ប្រភេទនៃសមត្ថភាពគ្រូបង្រៀនមានដូចតទៅ ÷

## ១_សមត្ថភាពខាងចំណេះដឹង

សមត្ថភាពចំណេះដឹង គឺជាសមត្ថភាពដែលបានមកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងអប់រំ ។

ជាទូទៅ មនុស្សដែលជាអ្នកមានជំនាញខាងចំណេះដឹង តែងតែយកអំណាចនៃចំណេះដឹងធ្វើជាឥទ្ធិពលលើអ្នកដទៃទៀត ។ ចំណេះដឹងរបស់គ្រូត្រូវបានសិស្សគោរពយ៉ាងងាយ ព្រោះពួកគេបានស្គាល់ចំណេះដឹងដ៏ទូលំទូលាយ និងជំនាញរបស់គាត់ ធ្វើអោយសិស្សពីមានអាកប្បកិរិយាច្រងេងច្រងាងនោះទៅជាមានវិន័យ ពោលគឺនឹងអាចទាក់ទាញអារម្មណ៍សិស្សអោយចូលចិត្តស្ដាប់គ្រូឡើងវិញ ។

## ២_សមត្ថភាពខាងទំនាក់ទំនងល្អ

សមត្ថភាពខាងទំនាក់ទំនងល្អ គឺជាសមត្ថភាពដែលជាលទ្ធផលបានមកពីទំនាក់ទំនងដែលគួរអោយកក់ក្ដៅជាមួយអ្នកដទៃផ្សេងៗទៀត ។ មនុស្សភាគច្រើនមាននិន្នាការទទួលយកដំបូន្មានល្អៗពីអ្នកដែលគេចូលចិត្ត និងអ្នកដែលគេគោរព ។

គ្រូមានសមត្ថភាពការងារខាងទំនាក់ទំនងល្អនៅពេលគ្រូនោះមានទឹកចិត្តរីករាយ ទំនាក់ទំនងអន្តរបុគ្គលល្អជាមួយបណ្ដាសិស្សដទៃទៀតនៅក្នុងថ្នាក់រៀន ចេះលើកទឹកចិត្តសិស្ស បញ្ចុះបញ្ចូលសិស្សអោយចូលចិត្តរៀន ។

## ៣_សមត្ថភាពខាងផ្លូវច្បាប់

សមត្ថភាពខាងផ្លូវច្បាប់ គឺចេះទាញយកគុណប្រយោជន៍ តួនាទីពិសេស ដែលបុគ្គលនោះកំពុងមានយកមកប្រើ ។ ឧទាហរណ៍: នាយកសាលា ប្រធាននាយកដ្ឋាន ចៅហ្វាយក្រុង... មានសមត្ថភាពអស្ចារ្យ ព្រោះអំណាចសាធារណៈដែលពួកគេកំពុងប្រើនៅនឹងដៃស្រាប់ ។ គ្រូត្រូវបានគេផ្ដល់ជូននូវសមត្ថភាពបែបនេះខ្លះៗតាមរយៈក្រុមប្រឹក្សាសាលា រដ្ឋបាល

សាលា។ គ្រូបង្រៀនមានសិទ្ធិធ្វើការសំរេចចិត្តក្នុងការគ្រប់គ្រងលើដំណើរការសិក្សា និងឥរិយាបថរបស់សិស្សច្រងេងច្រងាងនៅក្នុងថ្នាក់រៀន។ ជួនកាល លទ្ធផលនៃបទបញ្ជានេះមិនមែនបណ្តាលមកពីសិស្សទាំងអស់នោះ ទទួលនូវការគោរពសិទ្ធិទាំងនោះទេ។ សិស្សខ្លះក៏អាចប្រឆាំងការគ្រប់គ្រងរបស់គ្រូពីពេលមួយទៅពេលមួយផ្សេងទៀត។ ការទទួលសមត្ថភាពការងារខាងផ្លូវច្បាប់បានល្អប្រសើរ នៅពេលដែលពួកគេមានទំនាក់ទំនងវិជ្ជមានជាមួយសិស្សយ៉ាងសប្បាយរីករាយប្រកបដោយគតិយុត្តិ។

## ៤-សមត្ថភាពខាងផ្តល់រង្វាន់

សមត្ថភាពខាងផ្តល់រង្វាន់បានមកពីបុគ្គលម្នាក់ គឺជាលទ្ធផលនៃបំណិនផ្ទាល់ខ្លួនរបស់ពួកគេបានផ្តល់នូវអ្វីមួយដែលអ្នកដទៃផ្សេងទៀតប្រាថ្នាចង់បានដែរ។

ឧទាហរណ៍ : ពួកគេអាចទទួលរង្វាន់លើកទឹកចិត្ត ដូចជាប័ណ្ណសរសើរ ចំណាត់ថ្នាក់ និងជួនកាលជាទឹកប្រាក់។ សមត្ថភាពខាងរង្វាន់នេះ គ្រូត្រូវធ្វើដោយមានដែនកំណត់។ គ្រូមានរង្វាន់តិចតួច ត្រូវផ្តល់អោយពួកគេទៅតាមលទ្ធភាពរបស់គ្រូ ពោលគឺអ្វីដែលគ្រូយល់ថា ជារង្វាន់ ហើយមិនមែនជាអ្វីដែលសិស្សចង់បានតាមទំនើងចិត្តនោះទេ។ ចំពោះសិស្សដែលមិនខ្វាយខ្វល់នូវចំណាត់ថ្នាក់ដែលគេទទួលបាននៅក្នុងសាលារៀន គ្រូនឹងគ្មានឥទ្ធិពលអ្វីបន្តិចឡើយ ចំពោះសិស្សទាំងនោះ គ្រូជាអ្នកខិតខំប្រឹងប្រែងបង្ហាត់បង្រៀនគេស្ទើរគ្រប់ពេល។

## ៥-សមត្ថភាពខាងទណ្ឌកម្ម

សមត្ថភាពខាងទណ្ឌកម្ម គឺជាអំណាចមួយដែលបុគ្គលម្នាក់ៗត្រូវតែមាន ព្រោះអំណាចនេះគេធ្វើឡើងដើម្បីដាក់ទណ្ឌកម្ម។ ជាទូទៅ សេចក្តីសង្ឃឹមរបស់គ្រូលើសមត្ថភាពខាងទណ្ឌកម្មមិនគួរប្រើក្នុងបរិយាកាសថ្នាក់រៀនដែលគេចាត់ទុកថា ជាការងារល្អនោះទេ។ ទោះបីយ៉ាងណាក៏ដោយ គេអាចបង្កើតការទប់ស្កាត់ទូទៅមួយចំពោះគ្រូ និងកម្មវិធីសិក្សា មិនអោយប្រើការដាក់ទណ្ឌកម្មនេះទេ។ ការអនុវត្តនៃសមត្ថភាពដាក់ទណ្ឌកម្មមិនបានផ្តល់ដល់សិស្សជាមួយការបង្ខិតបង្ខំបង្ហាញហេតុផលជាបុគ្គលនោះទេ ដើម្បីអោយគេទទួលយកគំរូឥរិយាបថល្អទាំងនោះឡើងវិញ។ គ្រូបង្រៀនគិតពិចារណានូវបំណងប្រាថ្នាថែមទៀត។ សមត្ថភាពខាងទណ្ឌកម្ម គេអាចអនុវត្តទៅតាមស្ថានភាពជាក់ស្តែងដែលផ្តល់អោយ ជាការគាបសង្កត់លើឥរិយាបថសិស្សដែលធ្វើមិនដូចបំណងប្រាថ្នា ប៉ុន្តែឥរិយាបថមិនប្រក្រតីអាចកែលំអនៅពេលគេជំនួសដោយការដាក់ទណ្ឌកម្ម។

ជាទូទៅសមត្ថភាពចំណេះដឹង និងសមត្ថភាពទំនាក់ទំនង គឺជាសមត្ថភាពដែលគ្រូអាចស្វែងរកផលប្រយោជន៍ភាគច្រើនបំផុតក្នុងការអភិវឌ្ឍន៍ទំនាក់ទំនងការងារវិជ្ជមានជាមួយសិស្ស។ សិស្សជាទូទៅនឹងតស៊ូទទួលយកភាពជាអ្នកដឹកនាំនៃបុគ្គល និងជាអ្នកត្រូវដឹងដោយវិញ្ញាណក្លាយជាជំនាញ ហើយជាបុគ្គលមានការថែទាំយ៉ាងកក់ក្តៅ។

ការសន្និដ្ឋាននេះ ជាតំរូវការមួយសំរាប់គ្រូបង្រៀនអោយមានមូលដ្ឋានល្អនៅក្នុងវិជ្ជាជីវៈរបស់ខ្លួន។ ប្រភេទនៃប្រវត្តិនឹងត្រូវផ្តល់អោយពួកគេនូវតំរូវការទទួលស្គាល់គុណភាព ដើម្បីបង្កើតសមត្ថភាពចំណេះដឹងបន្ថែមលើនេះ។ គ្រូត្រូវការបង្កើតបរិយាកាសថ្នាក់រៀនជាវិជ្ជមាន នៅពេលសិស្សមានអារម្មណ៍ថា គ្រូខ្វល់ខ្វាយអំពីបុគ្គលិកលក្ខណៈរបស់សិស្ស។

**គោលការណ៍ជាមូលដ្ឋានខ្លះៗដ៏មានប្រសិទ្ធភាព :**

ដើម្បីទទួលបានជោគជ័យជាបន្តបន្ទាប់គ្រូបង្រៀនគួរគប្បីអនុវត្តតាមគោលការណ៍សំខាន់ៗមួយចំនួនដូចតទៅនេះ÷

### ក-កិត្តិយសរបស់សិស្សត្រូវបានគេការពារ

នៅពេលដែលគ្រូបង្រៀនកែលំអអាកប្បកិរិយាខុសឆ្គងរបស់សិស្ស សិស្សមិនគួរអៀនខ្មាស់ ឬមើលបំណាំចំពោះការអធិប្បាយដែលជាការណែនាំរបស់គ្រូ។ ការអធិប្បាយនេះ ក៏អាចជួយកាត់បន្ថយតំលៃផ្ទាល់ខ្លួនរបស់សិស្សពីអាកប្បកិរិយាខុសឆ្គងមកជាអាកប្បកិរិយាត្រឹមត្រូវ។ ការអត្ថាធិប្បាយរបស់គ្រូ ត្រូវមានសក្តានុពល ដើម្បីដឹកនាំកែលំអពង្រឹងវិន័យសិស្សឡើងវិញ។ ចរិតលក្ខណៈរបស់គ្រូ គឺជាគំរូ ដើម្បីជំរុញអោយសិស្សមើលឃើញកាន់តែច្បាស់ពីសេចក្តីថ្លៃថ្នូរ និងជាគំរូដល់សិស្ស ជៀសវាងការប្រើអំណាចគាបសង្កត់សិស្ស។ សិស្សដែលទទួលបរាជ័យ អាចមានអារម្មណ៍មិនសប្បាយចិត្តចំពោះការអត្ថាធិប្បាយរបស់គ្រូ ហើយគេចាត់ទុកថា ការអប់រំណែនាំ ការកាត់បន្ថយកំហុសរបស់គេ គឺជាការកាត់បន្ថយសេចក្តីថ្លៃថ្នូរ កិត្តិយសរបស់គេទៅវិញតាមរយៈសកម្មភាពគ្រូបង្រៀន។

តាមរបាយការណ៍របស់មនុស្សចាស់ម្នាក់ដែលជាអតីតសិស្សបាននិយាយថា ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលពួកគេបានកាត់បន្ថយ ឬកែលំអអាកប្បកិរិយាមិនសមរម្យរបស់ពួកគេ គឺបានមកពីសកម្មភាពគំរូ និងសកម្មភាពអត្ថាធិប្បាយរបស់គ្រូបង្រៀន។

### ខ-ការកែលំអបុគ្គល គឺជាលទ្ធភាពដ៏ល្អប្រសើរ ដើម្បីការកែតំរូវមនុស្សទូទៅ

វិធីមើលបំណាំគ្នាទៅវិញទៅមក គឺជាលទ្ធផលរបស់សិស្សដែលគេបានដឹងតាមរយៈវិញ្ញាណផ្ទាល់ខ្លួនគេ។ សិស្សធ្លាប់វាយប្រហារលើគ្រូ ក្នុងករណីដែលគ្រូបានកែតំរូវដាស់តឿនទៅលើសិស្សមានអាកប្បកិរិយាមិនសមរម្យនៅនឹងកន្លែង។ គ្រូត្រូវតែកែតំរូវលំអទៅលើសិស្សណាដែលមិនស្តាប់ដំបូន្មានគ្រូ ដើម្បីទុកជាគំរូដល់សិស្សដទៃទៀត។

ការកែតំរូវបុគ្គលម្នាក់ដែលមានឥរិយាបថមិនសមរម្យ អាចជាសម្ពាធមួយដែលផ្តល់ឱកាសអោយបុគ្គលនេះកែប្រែឡើងវិញ។ ផ្ទុយមកវិញ បើគ្រូប្រើពាក្យស្តីបន្ទោសជាសាធារណៈ សិស្សដែលមានកំហុសពិតជាមានអារម្មណ៍ថា គ្រូធ្វើអោយបាក់មុខមាត់ អាប់កិត្តិយសនៅចំពោះមុខមិត្តភក្តិគេ ជួនកាលបណ្តាលអោយមានការប្រទូស្តរាយគ្នារវាងសិស្ស និងគ្រូក៏អាចមាន។ បើគ្រូកែលំអសិស្សដែលមានកំហុសជាបុគ្គល គេពិតជាសប្បាយចិត្តនឹងកែប្រែ ហើយយកបញ្ហានេះទៅជម្រាបមិត្តភក្តិគេ ដើម្បីជាការកែតំរូវទូទាំងថ្នាក់។ ចំណែកឯទំនាក់ទំនងរវាងគ្រូ និងសិស្សក៏កាន់តែល្អប្រសើរឡើង ដើម្បីអាចទៅរកការពង្រឹងវិន័យដល់សិស្សដទៃទៀត។

### គ-មូលហេតុនៃអាកប្បកិរិយាច្រងេងច្រងាងត្រូវបានគេបង្ហាញ

ដើម្បីផ្លាស់ប្តូរនូវអាកប្បកិរិយាដែលមិនអាចទទួលយកបានមួយចេញ គេត្រូវតែបង្ហាញនូវមូលហេតុដែលនាំអោយមានឥរិយាបថច្រងេងច្រងាងនោះ។ ជាទូទៅ មូលហេតុសិស្សដែលមានអាកប្បកិរិយាច្រងេងច្រងាង គឺច្រើនបណ្តាលមកពីសកម្មភាពវិន័យ អាកប្បកិរិយា សមត្ថភាព និងសកម្មភាពផ្សេងៗទៀតរបស់គ្រូ រួមផ្សំជាមួយបទបញ្ជា ច្បាប់ទំលាប់ និងការគ្រប់គ្រងរបស់នាយកសាលា។

ឧទាហរណ៍ ៖ តំរោងមេរៀនដ៏អាក្រក់មួយ រួមជាមួយការរៀបចំថ្នាក់រៀនគ្មានសណ្តាប់ធ្នាប់ អាចជាការតំរង់ទិសសិស្សអោយមានឥរិយាបថមិនល្អ (ព្រោះសិស្សស្តាប់ខ្លឹមសារមេរៀនមិនបាន ក្នុងថ្នាក់រៀនគ្មានកន្លែងអង្គុយ ធុំក្លិនឆ្អាបឆ្អេះ។ល។)

ជួនកាលទៀត ការបង្ហាញអាកប្បកិរិយាច្រងេងច្រងាងរបស់សិស្ស គឺជាវិធីមួយដែលសិស្សស្វែងរកអ្នកដទៃអោយ

ជួយដោះស្រាយបញ្ហារបស់វា។ អាកប្បកិរិយាច្រលើសបើសរបស់សិស្ស អាចទាក់ទាញការប្រុងប្រយ័ត្នខ្ពស់របស់គ្រូអោយមានស្មារតីរហ័សរហួនត្រៀមលក្ខណៈដោះស្រាយ និងការពារជាទីបំផុត។ សិស្សនឹងមានឱកាសកែប្រែឥរិយាបថខុសឆ្គងរបស់គេក្នុងមធ្យោបាយណាមួយដែលគេបានស្គាល់ហេតុផលនៃកំហុសរបស់គេ តែគេមិនអាចកែបានភ្លាមៗនោះទេ។

**ឃ_ភាពច្បាស់លាស់ត្រូវបានរៀបចំឡើងរវាងអាកប្បកិរិយាច្រងេងច្រងាង**

មានឧប្បត្តិហេតុជាច្រើនដែលតែងតែកើតឡើងក្នុងសាលារៀន ដែលបណ្តាលមកពីបុព្វហេតុតូចៗរបស់សិស្ស។ គ្រូមិនត្រូវមានការឆេវឆាវចំពោះស្ថានភាពខុសគ្នារវាងកំហុសឆ្គងអាកប្បកិរិយាកិរិតស្រាល ហើយឈានទៅរកកំហុសធ្ងន់ធ្ងរដែលគេចាត់ទុកថា ជាទំលាប់ ឬជាជំនាញរបស់សិស្ស។ ការថែទាំត្រូវបានគេយកមកប្រើ ដើម្បីជៀសវាងនូវប្រតិកម្មចំពោះបញ្ហាតូចៗដែលគេអាចដោះស្រាយ ឬផ្សះផ្សាជាមួយសិស្សបាន។

គ្រូត្រូវកំណត់អោយច្បាស់លាស់ បញ្ហាណាតូច និងបញ្ហាណាធំ ដែលគួរដោះស្រាយ។ គ្រូត្រូវតែចាត់វិធានការទោះបីសិស្សមានបញ្ហាតូចក៏ដោយ ជៀសវាងកុំអោយបញ្ហានេះរាលដាលទៅជាបញ្ហាធំពិបាកដោះស្រាយ។

**ង_សិស្សត្រូវបានគេពន្យល់ថា ពួកគេបានជ្រើសរើសយកអាកប្បកិរិយាច្រងេងច្រងាង**

វាពិតជាមានសារៈសំខាន់ណាស់ ចំពោះសិស្សដែលបានយល់ដឹងពីលទ្ធផលនៃអាកប្បកិរិយាច្រងេងច្រងាង និងសកម្មភាពមិនទទួលខុសត្រូវផ្ទាល់ខ្លួន សកម្មភាពធ្វើតាមទំនើងចិត្ត និងការចង់តំនុំរបស់ពួកគេ។ គ្រូត្រូវពន្យល់ជួយតំរង់ទិសសិស្សអោយយល់ច្បាស់ ចេះមើលឃើញពីទំនាក់ទំនងល្អរវាងអាកប្បកិរិយាសមរម្យ និងលទ្ធផលរបស់វា។

តំរូវការសិស្សស្តីពីអាកប្បកិរិយាល្អៗដែលអាចទទួលយកបាន ត្រូវបានគេធ្វើការណែនាំអោយទទួលស្គាល់ និងមានភាពម្ចាស់ការទទួលខុសត្រូវ ជៀសវាងកុំប្រព្រឹត្តអយុត្តិធមិដល់សង្គម បង្កបញ្ហាដល់អ្នកដទៃ។ សិស្សត្រូវចេះទទួលយកកំហុសដោយខ្លួនឯងលើអ្វីដែលខ្លួនបានអនុវត្តខុស។

**ច_ចំលើយចំពោះអាកប្បកិរិយាមិនសមរម្យ មិនត្រូវបានស្អិតស្អេរ និងគ្មានយុត្តិធម៌**

គោលការណ៍បានបញ្ជាក់យ៉ាងច្បាស់ថា ចំលើយលើអាកប្បកិរិយាមិនសមហេតុផល ត្រូវបានទទួលពីគ្រូមកវិញព្រោះគ្រូជាអ្នកនៅផ្ទាល់ក្នុងថ្នាក់ជាមួយគ្នាស្ទើររាល់ថ្ងៃ។ បើសិនឥរិយាបថច្រងេងច្រងាង មិនត្រូវបានគ្រូយកចិត្តទុកដាក់អប់រំ នោះពិតជាសិស្សនោះគ្មានឱកាសកែប្រែខ្លួន ផ្តល់គំរូដល់មិត្តភក្តិក្នុងថ្នាក់រៀន ក្លាយជាសត្រូវរបស់មិត្តភក្តិ ក្លាយជាមនុស្សសង្គមមិនអោយតំលៃ មនុស្សបាត់បង់ថាមពល ត្រូវសង្គមរិះគន់ ពោលបាត់បង់ធនធានមនុស្សដ៏ល្អមួយក្នុងការកសាងសង្គម។ គោលការណ៍ពីរដែលផ្តល់ជាគំរូល្អគឺ :

-ទំនាក់ទំនងល្អគ្រូ និងសិស្ស ដែលគ្រូត្រូវតែលើកទឹកចិត្ត និងផ្តល់គំរូល្អៗដល់សិស្ស

-សិស្សគួរយកតំរាប់តាមសិស្សដទៃដែលមានគំរូល្អក្នុងថ្នាក់។

ដូច្នេះ ក្នុងការបង្ហាត់បង្រៀន គ្រូម្នាក់ៗគួរយកចិត្តទុកដាក់លើសមត្ថភាព និងគោលការណ៍ដែលបានរៀបរាប់ខាងលើ ដើម្បីអោយដំណើរការបង្រៀនក្នុងថ្នាក់មានវិន័យល្អប្រសើរ៕

**អនុបណ្ឌិត នួយ សូផាន**

# ទស្សនៈអប់រំ និងការស្វែងយល់ ចំពោះកុមារនៅក្នុងគ្រួសារ (តចប់)

## ៤-ការវិភាគទៅលើហេតុការណ៍នៃការអប់រំក្នុងគ្រួសារ

ដោយសំអាងទៅលើហេតុការណ៍ដែលស្គាល់លក្ខណៈពិសេសនៃការអប់រំកុមារនៅក្នុងគ្រួសារ និងឪពុកម្ដាយ អ្នកធ្វើការអប់រំចាំបាច់ត្រូវធ្វើការវិភាគយ៉ាងជ្រៅជ្រះពីអ្វីដែលបានឃើញ ស្ដាប់ឮ និងប្រើប្រាស់ទៅលើការអនុគ្រោះ ហើយបង្ហាញពីអ្វីដែលជាការរារាំងដល់ការអប់រំកុមារអោយបានត្រឹមត្រូវ។ អ្នកអប់រំ ត្រូវទាមទារចំពោះការអប់រំកុមារដោយការបញ្ចុះបញ្ចូលឪពុកម្ដាយអោយដើរតាមលក្ខខណ្ឌសំខាន់ក្នុងការអប់រំកុមារ ក្នុងទស្សនៈមួយលើកំរិតនៃការចេះដឹងផ្នែកគរុកោសល្យរបស់ឪពុកម្ដាយ ទាក់ទាញឪពុកម្ដាយអោយរួមចំណែកក្នុងការសិក្សាលក្ខណៈពិសេសរបស់កូន និងស្វែងរកហេតុផលវិជ្ជមាន និងអវិជ្ជមាន។

ផ្អែកតាមទស្សនកិច្ចនៅក្នុងគ្រួសារ គេអាចកំណត់បានទិសដៅខ្លះជាតួយ៉ាងនៃការរស់នៅ និងសភាពនៃការអប់រំកុមារនៅក្នុងគ្រួសារ។ ជាលទ្ធផលនៃការធ្វើអង្កេតគ្រួសារទាំងឡាយនៅក្នុងសហគមន៍មួយ គេបានកំណត់គ្រួសារជាក្រុមដូចតទៅ ÷

ក. គ្រួសារប្រកបដោយសុភមង្គល : ការទាមទារ និងការយកចិត្តទុកដាក់ចំពោះតំរូវការរបស់កុមារទៅលើសកម្មភាពរបស់គេ ដូចជាការសិក្សា ការបំពេញពលកម្ម ការលេងល្បែងកំសាន្ត គឺជាលក្ខណៈពិសេសតួយ៉ាងនៃគ្រួសារបែបនេះ។ កត្តាវិជ្ជមានបែបនេះ ត្រូវគេផ្ទួរផ្ទឹមជាមួយកំរិតនៃភាពដែលកុមារទទួលបានការអប់រំល្អ។ ការយកចិត្តទុកដាក់របស់ឪពុកម្ដាយចំពោះឱវាទគ្រឹះស្ថានអប់រំកុមារ សាលារៀន អ្នកធ្វើការអប់រំ និងគ្រួសារដែលមានទំនាក់ទំនងល្អរវាងមនុស្សពេញវ័យ និងកុមារ គ្រួសារដែលមានបទពិសោធល្អរស់នៅប្រកបដោយភាពសុខដុមរមនា គ្រួសារដែលស្រឡាញ់ការងារពលកម្ម ស្រឡាញ់វិស័យបច្ចេកទេស។ ពេលនោះហើយដែលធ្វើអោយកុមារចេះចូលរួមជួយធ្វើការងារឪពុកម្ដាយ កុមារនឹងសំដែងអាកប្បកិរិយាយ៉ាងប្រុងប្រយ័ត្ន និងហ្មត់ចត់ចំពោះការបំពេញភារកិច្ចរបស់ខ្លួន មានវិន័យល្អ ចេះសំដែងទឹកចិត្តគោរពញាតិមិត្ត ចាស់ទុំ គ្រូបាធ្យាយ។ ពេលនោះប្រសិនបើអ្នកធ្វើការអប់រំសួរថា "តើនៅផ្ទះបានធ្វើអ្វីខ្លះ" កុមារនឹងខិតខំប្រឹងប្រែងធ្វើការងារនៅផ្ទះ ដើម្បីរាយការណ៍ជូនដល់អ្នកអប់រំ។

ខ. គ្រួសារដែលប្រកបដោយសុភមង្គលមិនពេញលេញ : គ្រួសារបែបនេះ ទន្ទឹមគ្នានឹងទិសដៅជាអវិជ្ជមាននៃការអប់រំកុមារ ដូចជាការផ្ដល់ស្ថានភាព និងបរិយាកាស ពេលវេលាមិនសមស្របទៅនឹងគោលបំណង និងចំណង់ប្រាថ្នារបស់កុមារ ទោះបីកុមារមានគោលបំណងចង់ចូលរួមជួយធ្វើការងារឪពុកម្ដាយក៏ដោយ ប៉ុន្តែឪពុកម្ដាយពុំព្រមចូលរួមធ្វើជាមួយ រឺមិនទំលាប់ផ្ដល់អោយកូនធ្វើអ្វីៗដោយខ្លួនឯង ច្រើនធ្វើជំនួស។ បញ្ហានេះ អ្នកធ្វើការអប់រំត្រូវ

មានវិធីសំណេះសំណាលជួយផ្ដល់យោបល់ជូនទៅឪពុកម្ដាយ ដើម្បីអោយកុមារបានចូលរួមធ្វើការងារ និងកុំអោយឪពុកម្ដាយមានទស្សនៈមិនត្រឹមត្រូវទៅលើការចូលរួមរបស់កុមារ ។

គ- គ្រួសារប្រកបដោយសុភមង្គលតែខាងក្រៅ : ការចាប់អារម្មណ៍ជាលើកដំបូង អ្វីៗទាំងអស់ឃើញថាល្អប្រសើរ ក្រុមគ្រួសារឯកភាពចិត្តគំនិតគ្នារួមគ្នាធ្វើការ និងយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក ។ ប៉ុន្តែនៅពេលទស្សនកិច្ចរបស់អ្នកធ្វើការអប់រំ គេបានសំគាល់ឃើញថា ឪពុកម្ដាយសំដែងការមិនពេញចិត្តចំពោះកុមារដែលមានការរាប់អានមិត្តភក្តិរបស់កូន និងហាមប្រាមកូនមិនអោយដើរលេងជាមួយមិត្តភក្តិជាកុមារផងគ្នា ពេលនោះអ្នកធ្វើការអប់រំយល់ភ្លាមថា កុមាររស់នៅក្នុងភាពដ៏ចង្អៀតចង្អល់របស់ឪពុកម្ដាយ ជាហេតុដែលធ្វើអោយកុមារពុំមានចិត្តចង់ចូលរួមធ្វើការងារជាមួយឪពុកម្ដាយ និងគ្រួសារ និងធ្វើអោយកុមារមានចរិតរើសអើងក្នុងការងារ ។ អ្នកធ្វើការអប់រំត្រូវចេះរិះរកគ្រប់វិធី ដើម្បីពន្យល់ឪពុកម្ដាយអោយចេះផ្ដល់សិទ្ធិ និងការរស់នៅរបស់កុមារអោយរស់នៅតាមបែបផែនអប់រំក្នុងសង្គម ព្រោះកុមារចាំបាច់ត្រូវទទួលបានលទ្ធផលអប់រំក្នុងគ្រួសារ សាលារៀន សង្គម ពិសេសការចូលរួមប្រកបដោយប្រសិទ្ធភាព ។

ឃ- គ្រួសារមិនប្រកបដោយសុភមង្គលសោះ : ក្នុងស្ថានភាពបែបនេះ គឺផ្ដើមឡើងពីភាពកង្វះការចាត់តាំងដ៏ត្រឹមត្រូវសំរាប់ការរស់នៅរបស់កុមារ និងមើលស្រាលយ៉ាងជាក់ស្ដែងក្នុងការអប់រំកូន សូម្បីតែការថែទាំជាធម្មតាក៏ដោយ ។ ឪពុកម្ដាយតែងមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ និងប្រើនូវអំពើហិង្សាតាមផ្លូវកាយទៅលើកុមារទៀតផង ជាងនេះទៀត ឪពុកម្ដាយបានមើលស្រាលទៅលើឱវាទរបស់អ្នកធ្វើការអប់រំដែលលើកឡើងថា អំពើបែបនេះនឹងត្រូវជះឥទ្ធិពលយ៉ាងខ្លាំងទៅលើកុមារក្នុងគ្រួសារមួយទៀតដែលឪពុកម្ដាយចេញបាត់ពីផ្ទះពុំសូវបានយកចិត្តទុកដាក់អប់រំកូន រឹទង្វើរបស់កូននៅក្នុងគ្រួសារ ឪពុកម្ដាយពុំបានលើកទឹកចិត្ត ហើយចាត់ទុកថា ជាកំហុសរបស់កុមារដែលធ្វើការងារនោះ បញ្ហានេះហើយដែលធ្វើអោយកុមារបាត់បង់នូវគំនិតបញ្ញា ស្មារតី និងខ្វះការចូលរួម ។

### ៥-លទ្ធផលនៃទស្សនកិច្ចចំពោះគ្រួសារ

ការកត់ត្រាចេញពីគ្រួសារ ឪពុកម្ដាយ មានសារៈសំខាន់បំផុតក្នុងការបំពេញការងារនេះ គឺជួយអោយអ្នកធ្វើការអប់រំមើលឃើញពីលទ្ធផល និងការសន្និដ្ឋានសមហេតុផលតាមបែបផែនតរុកោសល្យ និងចាត់ទុកជាភារកិច្ចជាក់លាក់សំរាប់ការអប់រំកុមារ ដើម្បីវាយតំលៃកូនល្អក្នុងគ្រួសារ ។

ជាញឹកញាប់បំផុត អ្នកអប់រំត្រូវគ្រោងទុកផែនការច្បាស់សំរាប់ធ្វើការងារជាមួយគ្រួសារតាមទស្សនៈការអប់រំកុមាររយៈពេលខ្លីៗជាមួយគ្រួសារ ដោយមានកំណត់ហេតុនៅក្នុងសៀវភៅសរសេរមួយដោយឡែកសំរាប់ការចុះទស្សនកិច្ចកុមារនៅតាមគ្រួសារ ៕

លោកស្រី អ៊ឹម សុផល្លី

អនុប្រធានការិ.យុវជន និងកីឡា នាយកដ្ឋានយុវជន




# ប្រទេសដែលបង្កើតសំភារៈបរិក្ខារមុនគេ បន្ទាប់ក្នុងអំឡុងពេលបដិវត្តន៍ឧស្សាហកម្ម

| ឈ្មោះប្រទេស | សំភារៈបរិក្ខារ | ឆ្នាំបង្កើត |
|---|---|---|
| អង់គ្លេស | ម៉ាស៊ីនដេរ | ១៧៦៤ |
| អង់គ្លេស | ម៉ាស៊ីនចំហាយទឹក | ១៧៧៦ |
| ស្កុតឡែន | ម៉ាស៊ីនបោកស្រូវ | ១៧៨៦ |
| សហរដ្ឋអាមេរិក | កប៉ាល់ប្រើចំហាយទឹក | ១៨០២ |
| អាល្លឺម៉ង់ | ម៉ាស៊ីនបោះពុម្ព | ១៨១១ |
| អង់គ្លេស | ស៊ីម៉ងត៍ | ១៨២៤ |
| អង់គ្លេស | រថភ្លើងប្រើចំហាយទឹក | ១៨២៥ |
| អង់គ្លេស | ម៉ាស៊ីនភ្លើងអគ្គិសនី | ១៨៣១ |
| សហរដ្ឋអាមេរិក | ម៉ាស៊ីនច្រូតកាត់ | ១៨៣៤ |
| បារាំង | ម៉ាស៊ីនថតរូប | ១៨៣៩ |
| សហរដ្ឋអាមេរិក | ម៉ាស៊ីនទូរលេខ | ១៨៤៤ |
| បារាំង | ម៉ាស៊ីនប្រើសាំង | ១៨៥៩ |
| សហរដ្ឋអាមេរិក | ជណ្ដើរយន្ត | ១៨៦១ |
| អាល្លឺម៉ង់ | រថយន្តប្រើសាំង | ១៨៧៦ |
| សហរដ្ឋអាមេរិក | ទូរស័ព្ទ | ១៨៧៦ |
| អាល្លឺម៉ង់ | ម៉ាស៊ីនម៉ាស៊ូត | ១៨៩២ |
| សហរដ្ឋអាមេរិក | កុន | ១៨៩៣ |

អូន ស៊ីឡុត សាស្ត្រាចារ្យឯកទេសភាសាអង់គ្លេស
វិ.ហ៊ុន សែន បល្ល័ង្កកំពង់ធំ

ប្រភព : Geography "Paul Ward English"




## វិធីបង្រៀន និងកម្មវិធីសៀវភៅសិក្សាភាសាខ្មែរ នៅបឋមសិក្សាបំពេញវិជ្ជាពី១៩៥៣-១៩៧០ (ត)

### គ-សារៈសំខាន់នៃវិធីបង្រៀនផ្ទាល់

វិធីនេះធ្វើអោយការបង្រៀនមានលក្ខណៈរូបី ជៀសវាងវាទនិយម (ការនិយមថា សម្ដីសំខាន់ជាងគំនិត) ចំណេញពេលវេលា លើកសរសើរការយល់ដឹងរបស់សិស្ស ធ្វើអោយថ្នាក់រៀនមានភាពសកម្ម និងរស់រវើក ធ្វើអោយក្មេងសប្បាយរីករាយ ហើយវាក៏ប្រយុទ្ធនឹងភាពរាយមាយ និងការធុញទ្រាន់។

ជារួម យើងឃើញថា វិធីអព្ភន្តរញាណ និងវិធីបង្រៀនផ្ទាល់ សុទ្ធតែជាវិធីដែលគ្រូជាអ្នកដាក់បញ្ហាដល់សិស្ស។ វាជាមូលដ្ឋាននៃចិត្តវិទ្យាទូទៅ និងចិត្តវិទ្យាកុមារ វាមានប្រសិទ្ធភាពខ្លាំងណាស់ ហើយវាបំរើតាមសំណូមពរគោលបំណងនៃសាលាបឋមសិក្សាអោយបានសម្រេចតាមគោលដៅ។

ការបង្រៀនដោយប្រើវិធីផ្ទាល់នេះ គេអាចកាត់បន្ថយការនិយាយរ៉ាយរ៉ាប់វែងឆ្ងាយ នាំអោយខាតពេលវេលា នាំអោយសិស្សធុញទ្រាន់។ វាជាវិធីមួយដែលប្រើរូបភាព ឬភាពរូបី ឬអព្ភន្តរញាណមកជំនួសដូចជា ដើម្បីពន្យល់អោយសិស្សយល់អំពីសត្វក្របី។ គ្រូត្រូវរ៉ាយរ៉ាប់ពន្យល់សិស្សថា ក្របីជាសត្វជើងបួនដូចសត្វគោ មានស្នែងដូចសត្វគោ តែស្នែងវាធំជាង ជាទូទៅវាមានពណ៌ខ្មៅ។ វាជាសត្វស៊ីស្មៅជាអាហារ វាចូលចិត្តដេកក្នុងភក់ ឬទឹក ថ្លុកត្រពាំង។ ប៉ុន្តែបើសិនជាគ្រូមានរូបភាពសត្វក្របី ឬក្របីផ្ទាល់តែម្ដង មកបង្ហាញសិស្ស នោះធ្វើអោយសិស្សយល់ភ្លាមដោយមិនបាច់ពន្យល់ច្រើន។ វិធីនេះ ជាវិធីដ៏សំខាន់ក្នុងការបង្រៀនភាសាខ្មែរ ជាពិសេសនៅក្នុងការបង្រៀនពាក្យ ឬអំណាន។

សរុបមក វិធីបង្រៀននេះជាបុព្វបុរសនៃវិធីបង្រៀនតាមរូបីកម្ម ហើយក៏ជាគ្រឹះនៃគោលវិធីសិស្សមជ្ឈមណ្ឌលសព្វថ្ងៃនេះដែរ។ ដូច្នេះ ក្នុងម៉ោងបង្រៀនសិស្ស ទាមទារអោយគ្រូមានសម្ភារៈឧបទេសសម្បូរបែប ទើបធ្វើឱ្យសិស្សចាប់អារម្មណ៍លើម៉ោងបង្រៀនរបស់ខ្លួន ហើយធ្វើអោយសិស្សរៀនឆាប់ចេះ ឆាប់ចាំ និងឆាប់យល់ ហើយអាចអនុវត្តបានដោយត្រឹមត្រូវផង ព្រមទាំងអាចក្រេបយកពុទ្ធិទៅបម្រើក្នុងជីវភាពរស់នៅបាន។

## ខ.វិធីសកម្ម

វិធីសកម្ម គឺជាវិធីមួយដែលប្រឆាំងដាច់ខាតនឹងវិធីមួយដែលគេហៅថា វិធីបង្រៀនតាមប្រពៃណី គ្រូជាអ្នកបង្គាប់បញ្ជាទាំងស្រុង និងបង្រៀនតាមតែសៀវភៅ។ វិធីបង្រៀននេះ នាំអោយសិស្សប្រើអស់សរីរាង្គឥន្ទ្រីយ៍ កម្លាំងកាយ ឬសាច់ដុំ បញ្ញា ចិត្តរបស់គេ បង្កើតអោយមានការសង្កេត ការធ្វើសកម្មភាព ការឆ្លុះបញ្ចាំងរិះគិត ការប្រើរូបារម្មណ៍ ហើយនិងសញ្ចេតនា។ វិធីបង្រៀននេះ ធ្វើអោយការបង្រៀនមានភាពសកម្ម និងរស់រវើក។ វិធីបង្រៀននេះអនុវត្តបានតាមសំណូមពរ បើសិនជាគ្រូបានគោរពតាមបុគ្គលិកលក្ខណៈសិស្ស និងបច្ចេកទេសដ៏សំខាន់ និងគ្មានការបង្ខិតបង្ខំសិស្ស។

នៅក្នុងវិធីសកម្មនេះ គ្រូត្រូវចេះ និងយល់ដឹងអំពីមូលដ្ឋានចិត្តសាស្ត្រនៃវិធីសកម្ម សកម្មភាព និងចលនារបស់កុមារដែលប្រែប្រួលតាមចំណូលចិត្តកុមារ ជីវភាពពិសេសរបស់កុមារ លក្ខណៈពិសេសនៃវិធីសកម្ម ការប្រើប្រាស់វិធីសកម្ម។

ដើម្បីអោយវិធីសកម្មនេះមានប្រសិទ្ធភាពក្នុងការបង្រៀន និងដឹកនាំសិស្ស គ្រូត្រូវអនុវត្តនូវល្បិចផ្សេងៗទៀតដូចជា : ការសិក្សាពីមជ្ឈដ្ឋាន ការធ្វើអង្កេត និងដំណើរកំសាន្តសិក្សា ការធ្វើកិច្ចតែងការបង្រៀន ការសិក្សាតាមរយៈការធ្វើការងារជាក្រុម ទិនានុប្បវត្តិសិក្សា និងការបោះពុម្ពប្រចាំសាលារៀន ទំនាក់ទំនង និងការផ្លាស់ប្តូរអន្តរសាលារៀន ស្វ័យគ្រប់គ្រង សមាគម និងចលនាយុវជន។ ក្រៅពីនេះ គេក៏បានបង្ហាញល្បិចខ្លះៗក្នុងការបង្រៀនមុខវិជ្ជាផ្សេងៗដូចជា តែងសេចក្តី ភាសា ប្រវត្តិវិទ្យា ភូមិវិទ្យា និងការបង្រៀនមេរៀន តាមការប្រើប្រាស់វត្ថុស្វាធ្យាយ[១] ។

ទាំងនេះបញ្ជាក់អោយឃើញថា វិធីបង្រៀនបែបទំនើបដែលយកសិស្សមជ្ឈមណ្ឌលនៃសកម្មភាពបានចាប់ផ្តើមហើយ ថ្វីបើការប្រើប្រាស់នៅមិនទាន់បានទូលំទូលាយ មិនទាន់មានប្រសិទ្ធភាពទាំងស្រុងក្តី វាក៏ជារបត់ថ្មីមួយដែលខ្មែរបានទទួលនូវកំណែប្រែថ្មីសន្ធាងមួយ ក្រោយពេលខ្លួនបានទទួលឯករាជ្យពីពួកអាណានិគមនិយមបារាំង។ វិធីសកម្មចាប់ផ្តើមសិក្សាយល់ស៊ីជំរៅនូវមូលដ្ឋានចិត្តសាស្ត្ររបស់កុមារជាវ័យក្មេងខ្ចី ដែលត្រូវតែយកចិត្តទុកដាក់គ្រប់សកម្មភាពរបស់គេ។កុមារចូលចិត្តធ្វើចលនា ហើយចលនានោះប្រែប្រួលទៅតាមចំណូលចិត្តរបស់គេ។ កុមារសប្បាយរីករាយ ពេលបានធ្វើសកម្មភាព បានអនុវត្តផ្ទាល់។ វាភ័យខ្លាចការបង្ខំអោយនៅស្ងៀម។ ការសិក្សាមួយដែលមានភាពអកម្ម មិនអាចធ្វើអោយកុមារទទួលបានពុទ្ធិរឹងមាំទេ។ ក្រៅពីនេះ ដើម្បីសម្រេចវិធីនេះបានល្អ ក៏ត្រូវទាមទារអោយគ្រូមានសមត្ថភាពគ្រប់គ្រាន់ សម្ភារៈសិក្សា និងសម្ភារៈឧបទេសគ្រប់គ្រាន់ផងដែរ។

សរុបមកវិញ វិធីបង្រៀនទូទៅនៅក្នុងសម័យសង្គមរាស្ត្រនិយម បានរីកចំរើនយ៉ាងខ្លាំងក្លា ហើយដោយសម័យនោះខ្មែរយើងបានទទួលឯករាជ្យ មានភាពម្ចាស់ការលើការកសាងប្រទេស។ វិធីបង្រៀនទាំងនោះ ត្រូវបានសម័យក្រោយៗទៀត យកមកសិក្សាមិនអាចរំលងចោលបាន ដូចជាសម័យសាធារណរដ្ឋខ្មែរ និងសម័យរាជាណាចក្រកម្ពុជាទី២ ជាដើម។

ថ្វីបើក្នុងសម័យនោះ ការអនុវត្តវិធីបង្រៀនភាគច្រើន គឺប្រើគោលវិធីគ្រូមជ្ឈមណ្ឌល ដែលគ្រូជាអ្នកបង្គាប់

(១) Cf. Ministère de l'Education Nationale, Cours de perfectionnement pédagogique, op.cit., p.29-40

បញ្ហាជាអ្នកផ្ដល់ពុទ្ធិទាំងស្រុងទៅអោយសិស្សក្ដី ក៏ការវិវត្តនៃវិធីបង្រៀនបានកែប្រែច្រើនហើយ ជាក់ស្ដែងដូចខ្លឹមសារវិធីសកម្មដែលបានរៀបរាប់កន្លងមកហើយ។ ការសិក្សាតាមសកម្មភាពក្រុម ក៏បានចាប់ផ្ដើម គឺមានន័យថាគោលវិធីសិស្សមជ្ឈមណ្ឌលបានចាប់ផ្ដើមបញ្ច្រាបដល់គ្រូបង្រៀន ហើយជាពិសេសនៅក្នុងវិធីសកម្មក៏មានរៀបរាប់ពីការសិក្សាស្វែងយល់ពីមជ្ឈដ្ឋាន និងការធ្វើអង្កេត និងដំណើរកំសាន្តសិក្សាផងដែរ។ ក្រៅពីនេះ ក៏មានវិធីបង្រៀនផ្ទាល់ដែលប្រើលក្ខណៈរូបី ឬប្រើប្រាស់រូបភាពវត្ថុពិត ។ល។ ដែលទាក់ទងដល់ចំណេះដឹងផ្នែកអព្ភន្តរញាណ ដើម្បីអភិវឌ្ឍបញ្ញារបស់សិស្ស។

ម្យ៉ាងវិញទៀត នៅក្នុងគរុកោសល្យទូទៅ ក៏បានបង្ហាញពីវិន័យ ទណ្ឌកម្ម និងការផ្ដល់រង្វាន់ដល់សិស្សផងដែរ។ វិន័យត្រូវមានលក្ខណៈសេរី មិនត្រូវបង្ខិតបង្ខំ ដោយកម្លាំង តែត្រូវមានការស្រុះស្រួលគ្នា មានន័យថា វិន័យត្រូវអោយសិស្សយល់ដឹង និងព្រមទទួលដោយសុទ្ធចិត្ត។ ចំណែកទណ្ឌកម្មមានត្រឹមការព្រមាន ការស្ដីបន្ទោស តែប្រសិនបើមានកំហុសធ្ងន់ធ្ងរ មិនអាចកែកំហុសបាន គឺលុបឈ្មោះសិស្សនោះជាស្ថាពរ។ ទណ្ឌកម្មក៏ត្រូវជៀសវាងលើរូបរាងកាយ ដូចជាវាយដោយរំពាត់ ដំបង ឬដោយប្រើដៃជើងអោយឈរនៅក្នុងថ្នាក់ ។ល។ ផ្ទុយទៅវិញ សិស្សដែលប្រឹងប្រែងរៀនសូត្រ គោរពវិន័យក៏ត្រូវទទួលបានរង្វាន់ដែរ ដូចជាការលើកសរសើរផ្ទាល់មាត់ ប័ណ្ណសរសើរ ។ល។

រួមសេចក្ដីមក វិធីបង្រៀនទូទៅក្នុងសម័យសង្គមរាស្ត្រនិយម បានឈានផុតពីភាពអវិជ្ជមាន ភាពអសកម្មទាំងឡាយ ដែលមានពីសម័យមុនៗដូចជា សម័យអាណានិគមនិយមបារាំង។ ការវិលទៅនិយមភាសាជាតិ នៅគ្រប់ភូមិសិក្សា ក៏ជាភាពវិសេសមួយនៅក្នុងសម័យនោះដែរ។ ភាពល្អប្រសើរទាំងអស់ខាងលើនេះ ជនគ្រប់រូបនៅក្នុងសម័យនោះ និងសង្គមក្រោយៗមកទៀត ក៏ទទួលស្គាល់ដែរ។

(នៅមានត)

អនុបណ្ឌិត ស្វ ស្វធីរ

---

មានបុរសម្នាក់ជាមនុស្សកំណាញ់បំផុត។ គាត់មានស្វាយមួយដើម ផ្លែទុំមានរសជាតិផ្អែមរកគ្មានដូច។ អ្នកស្រុកជិតឆ្ងាយដាក់ងារអោយគាត់ថា "តាស្វាយផ្អែម"។ អ្នកស្រុកជាច្រើនចង់បានគ្រាប់ស្វាយទុំរបស់គាត់ទៅធ្វើពូជ តែសុំក៏មិនបាន ទិញក៏មិនលក់។ ពេលស្វាយគាត់មានផ្លែទុំ គាត់ការពារទាំងយប់ ទាំងថ្ងៃដោយប្រុងប្រយ័ត្នបំផុត ហើយបើមានអ្នកណាទៅអង្វរសុំទិញ គាត់សុខចិត្តអោយភ្លក្សសាច់មួយចំណិត ឯគ្រាប់គាត់មិនអោយជាដាច់ខាត។ ថ្ងៃមួយមានយុវជនម្នាក់ធានាថា នឹងយកស្វាយផ្អែមនោះមកធ្វើពូជទាល់តែបាន ទីបំផុតក៏យកបានមែន។

តើយុវជននោះយកពូជស្វាយផ្អែមបានដោយវិធីណា?

ចំលើយនៅទំព័រ ២៨

ផាត់ សាំ

# ការណែនាំគរុកោសល្យ (ត)

## II. តួនាទីរបស់គ្រូឧទ្ទេស

គ្រូឧទ្ទេសមានតួនាទី ៣ យ៉ាង គឺ÷

១- ជាវាគ្មិនម្នាក់យ៉ាងចំណានក្នុងការធ្វើបទឧទ្ទេស ពោលគឺប៉ិនប្រសប់ផ្តល់ពតិមាន ពន្យល់ និងទាក់ទាញសិក្ខាកាម ។

២- ជាអ្នកគរុកោសល្យដែលស្ទាត់ជំនាញក្នុងការរៀបចំគោលដៅគរុកោសល្យ ។

៣- ជាអ្នកចលនាក្រុមដែលស្ទាត់ជំនាញក្នុងការយល់ដឹងអំពីប្រតិកម្មរបស់ក្រុម ។

*** ការកំណត់មុខសញ្ញា**

គ្រូឧទ្ទេសត្រូវស្វែងយល់អោយឃើញច្បាស់នូវមុខសញ្ញាដែលត្រូវបំប៉នតាមរយៈការសង្កេត ការស្រង់ពតិមានពីនាយកសាលា ការពិនិត្យកិច្ចការ ការពិនិត្យមិជ្ឈភាពថ្នាក់ ។ល ។ តើគេមានចំណុចខ្វះខាតអ្វីខ្លះដែលត្រូវជួយដូចជា÷

**ក. លើខ្លឹមសារមេរៀន**

តើគ្រូណាខ្លះដែលក្តាប់ខ្លឹមសារមេរៀនមិនទាន់ច្បាស់លាស់? តើគ្រូណាខ្លះដែលមិនអាចដោះស្រាយបណ្តាបញ្ហាក្នុងសៀវភៅសិក្សារបស់ក្រសួងអប់រំបានអស់? គ្រូបង្រៀននៅថ្នាក់ណាខ្លះ? មានប៉ុន្មាននាក់?

**ខ. លើសកម្មភាពបង្រៀន**

តើគ្រូណាខ្លះដែលមិនទាន់ច្បាស់លាស់ក្នុងការធ្វើកិច្ចតែងការបង្រៀន មិនទាន់ចេះកំណត់គោលបំណងមេរៀន មិនទាន់ចេះប្រើវិធីសាស្ត្រ រឺល្បិចបង្រៀនតាមមុខវិជ្ជា មិនទាន់ចេះកសាង និងប្រើប្រាស់សំភារឧបទេសអោយសមស្របតាមខ្លឹមសារមេរៀនពនីមួយៗ?

**គ. លើអាកប្បកិរិយា**

តើគ្រូណាខ្លះដែលមិនទាន់ផ្តល់ការងាយស្រួល ការទុកចិត្ត និងភាពកក់ក្តៅដល់សិស្សតាមរយៈពាក្យសំដី ទឹកមុខ និងកាយវិការ?

*** ការកំណត់រូបភាព** : គ្រូឧទ្ទេសត្រូវកំណត់អោយបានច្បាស់លាស់ថា តើត្រូវរៀបចំបើកការប្រជុំគរុកោសល្យ រឺបើកសិក្ខាសាលា ព្រោះការបើកសិក្ខាសាលាបានគួរតែមានសមាជិកចូលរួមប្រហែលជា ៣០នាក់ឡើងទៅ ។

មុនបើកសិក្ខាសាលាត្រូវគិតគូរជាមុននូវ÷

**១-ពេលវេលា និងទីកន្លែង**

ក. ពេលវេលា :

- ការប្រជុំគួរបង្កលក្ខណៈអោយបានគ្រប់គ្រាន់ ដើម្បីអោយសិក្ខាកាមស្វែងយល់នូវបណ្តាបទពិសោធន៍ពីគ្នាមេរិញទៅមក ក្តាប់បាននូវគោលការណ៍គ្រឹះ ដើម្បីយកទៅអនុវត្តតាមមូលដ្ឋាន

អោយមានប្រសិទ្ធភាព។ គ្រូឧទ្ទេសត្រូវចេះកំណត់ពេលវេលានៃការប្រជុំ វីសិក្ខាសាលាទៅតាមខ្លឹមសារ និងគោលបំណងតិច ឬច្រើន។

- ការប្រជុំមានរយៈពេលពី១ថ្ងៃ ឬ២ថ្ងៃ តែចំពោះសិក្ខាសាលាវិញអាចមានរយៈពេលច្រើនថ្ងៃ។ ក្រៅពីនេះ គ្រូឧទ្ទេសត្រូវគិតពីការអញ្ជើញអ្នកចូលរួម តើត្រូវមានសមាសភាពណាខ្លះ? មានចំនួនប៉ុន្មាននាក់? ចូលរួមមានរយៈពេលប៉ុន្មានថ្ងៃ? ពីថ្ងៃណាដល់ថ្ងៃណា? ចប់នៅថ្ងៃណា? ម៉ោងប៉ុន្មាន? ហើយសិក្ខាកាមត្រឡប់ទៅវិញនៅថ្ងៃណា?

**១. ទីកន្លែង**

ក្រោយពីក្តាប់បាននូវបណ្តាពតិមាន ចំណុចល្អ ចំណុចខ្វះខាត គ្រូឧទ្ទេសចាំបាច់ត្រូវរៀបចំប្រមូលផ្តុំបណ្តាមុខសញ្ញាបែងចែកតាមប្រភេទសមាសភាព ហើយរៀបចំការប្រជុំ វីសិក្ខាសាលាដោយគិតពីការធ្វើដំណើរងាយស្រួលដល់អ្នកចូលរួមបានឆាប់រហ័ស ធានាសុវត្ថិភាពក្នុងការធ្វើដំណើរ ការស្នាក់នៅ និងការហូបចុកដល់សិក្ខាកាម។

**២-សកម្មភាពសារវ័ន**

- ការប្រជុំគរុកោសល្យ វីសិក្ខាសាលា គឺជាកិច្ចការសំខាន់បំផុតរបស់គ្រូឧទ្ទេស។ ដើម្បីលើកស្ទួយកិច្ចការទាំងពីរនេះ តើគ្រូឧទ្ទេសត្រូវមានទំនាក់ទំនងការងារជាមួយអ្នកណាខ្លះ? តាមរបៀបណា? គួរគិតគូរដល់បញ្ហាអ្វីខ្លះ ដែលមានចំពោះមុខ?
- ក្រោយពីបានសំរេចថា ការណែនាំគរុកោសល្យ វីសិក្ខាសាលាហើយ គ្រូឧទ្ទេសត្រូវជ្រើសរើសទីកន្លែងដែលមានលក្ខណៈសមស្របទាំងសំភារៈមូលដ្ឋាន ទាំងការស្នាក់នៅ និងផ្លូវគមនាគមន៍។ លុះបានធ្វើការជ្រើសរើសទីកន្លែងបានរួចហើយ គ្រូឧទ្ទេសត្រូវទំនាក់ទំនងតាមខ្សែរយៈ ដូចជាការិយាល័យអប់រំ យុវជន និងកីឡាខ័ណ្ឌ-ស្រុកអោយធ្វើអន្តរាគមន៍ទៅនាយកសាលា អោយរៀបចំតាមសំណូមពររបស់យើង។
- គ្រូឧទ្ទេសត្រូវជ្រើសរើសមុខសញ្ញាដែលត្រូវស្នើឡើងក្នុងពេលធ្វើបទអន្តរាគមន៍ ហើយគ្រូឧទ្ទេសគួរអោយដំបូន្មានល្អៗជាមុនសិន ដើម្បីធ្វើទុនសំរាប់យកទៅធ្វើបទពិសោធន៍។
- បើសិនជាអាចធ្វើបានគួរតែទៅមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ដើម្បីសុំយោបល់មួយចំនួនទៀតទុកជាគំនិតរួមមួយក្នុងការធ្វើអោយបានសំរេចលទ្ធផលល្អប្រសើរថែមទៀត។

ក. ការប្រជុំគរុកោសល្យ វីសិក្ខាសាលា : គឺជាបញ្ហាសំខាន់ដែលត្រូវយកចិត្តទុកដាក់ ពោលគឺធ្វើអោយការណែនាំគរុកោសល្យទទួលបានលទ្ធផលខ្ពស់ ។ចំពោះបញ្ហានេះ យើងគប្បីត្រៀមលក្ខណៈអោយបានល្អប្រសើរដូចជា:

- **គោលបំណង** : គឺជាគន្លឹះសំខាន់ដែលត្រូវកំណត់អោយបានច្បាស់លាស់ថា តើគ្រូឧទ្ទេសចង់បានចំណុចអ្វីខ្លះ ទិសដៅអ្វីខ្លះសំរាប់អនុវត្ត បើគ្រូឧទ្ទេសរកគោលបំណងមិនបានច្បាស់លាស់ទេ នោះការប្រជុំគរុកោសល្យ វីសិក្ខាសាលាក៏គ្មានប្រសិទ្ធភាពដែរ។
- **គ្រូឧទ្ទេស** : ជាគ្រូដែលបានទទួលការបណ្តុះបណ្តាលពេញលេញ មានបទពិសោធន៍គ្រប់គ្រង

ហើយជាអ្នកមានមនសិការ និងមានសមត្ថភាពគ្រប់គ្រាន់។

- **អ្នកទទួលខុសត្រូវ** : ចាំបាច់ត្រូវមានអ្នកទទួលខុសត្រូវ ដើម្បីងាយស្រួលលើការគ្រប់គ្រងណែនាំរាល់បណ្តាចំណុចនីមួយៗ។ អ្នកទទួលខុសត្រូវ គឺជាមនុស្សឆ្លាតវាងវៃ ប៉ិនប្រសប់ ធ្វើកម្មវិធីចាត់តាំងអនុវត្តបានល្អ។
- **ខ្លឹមសារ** : ខ្លឹមសារត្រូវបំរើអោយទិសដៅរួមរបស់ការប្រជុំ វិសិក្ខាសាលា។ ចង់និយាយថា បើគ្រូឧទ្ទេសកំណត់ខ្លឹមសារមិនបានច្បាស់លាស់នោះ រូបភាពនៃកិច្ចការទាំងពីរពិតជាបរាជ័យ។ ដូចនេះ គេគប្បីរកអោយឃើញចំណុចពិបាកកន្លងមកដែលសិក្ខាកាមមិនអាចអនុវត្តកន្លងមកបាន។ ខ្លឹមសារត្រូវមានលក្ខណៈជាប្រយោជន៍ និងប្រើប្រាស់បាន។
- **ទីកន្លែង** : សមស្របតាមមូលដ្ឋានជាក់ស្តែង មិនគប្បីយកសាលាដែលជួបការលំបាកក្នុងការប្រជុំវិសិក្ខាសាលាឡើយ ព្រោះសិក្ខាកាមត្រូវធ្វើដំណើររកកន្លែងសំរាក បន្ទប់សិក្សា។ល។
- **ពេលវេលា** : គប្បីលំអិតកម្មវិធីអោយបានច្បាស់លាស់ ទើបរៀបចំធ្វើកម្មវិធីបានសមស្រប។ ដូចនេះ គួរយកពេលវេលា ២រឺ៣ថ្ងៃសំរាប់ប្រជុំ ឬសិក្ខាសាលាដើម្បីអោយដំណើរការបានល្អ។
- **បរិក្ខារ** : ដើម្បីលើកស្ទួយការប្រជុំ វិសិក្ខាសាលាអោយបានល្អ ត្រូវគ្រប់គ្រងទទួលខុសត្រូវ គួររៀបចំថវិកាបន្ថែមទៀត ទើបមានភាពងាយស្រួលអោយសិក្ខាសាលាមានទឹកចិត្តផុសផុលចូលរួមរៀនសូត្របានល្អ។

១. ដើម្បីអោយដំណើរការប្រជុំ វិសិក្ខាសាលាប្រព្រឹត្តទៅដោយជោគជ័យ គ្រូឧទ្ទេសត្រូវរៀបចំគំរោងអោយបានច្បាស់លាស់ និងត្រឹមត្រូវលើ :

- ប្រធានបទការប្រជុំ វិសិក្ខាសាលា
- គោលបំណង
- ខ្លឹមសារដែលត្រូវឧទ្ទេស
- ត្រៀមអ្នកធ្វើបទអន្តរាគមន៍
- រៀបចំសំណួរពិភាក្សា
- ចាត់តាំងអ្នកកាន់កម្មវិធី
- ចាត់តាំងគណៈអធិបតី ភ្ញៀវចូលរួម និងលេខាកត់ត្រា។

(នៅមានត)

**លោក ឆេង ឡឿន**
**ប្រធានការិ.អប់រំ និងគ្រប់គ្រង**
**នៃវិទ្យាស្ថានជាតិអប់រំ**

# កំណែលំអសាលារៀន : ជំហានដំបូងមួយ

*"កែលំអសាលារៀន"* ពាក្យនេះត្រូវបានឮជាដដែលៗរាប់ឆ្នាំមកហើយនៅកម្ពុជា ហើយយុទ្ធវិធីជាបន្តបន្ទាប់ត្រូវបានប្រកាន់យកដើម្បីធ្វើអោយវិស័យអប់រំកាន់តែបានប្រសើរឡើង។ សៀវភៅមួយចំនួនទាក់ទងទៅនឹង*ការងារគ្រប់គ្រងសាលារៀន* ក៏ត្រូវបានបោះពុម្ពផ្សាយ។ កម្មវិធីបំប៉នជាច្រើនក៏ត្រូវបានអនុវត្ត។ ការប្រែប្រួលជាវិជ្ជមានមួយចំនួនក៏ត្រូវបានស្តែងឡើងគួរអោយកត់សំគាល់។ ប៉ុន្តែទោះបីយ៉ាងណា ក៏ការប្រែប្រួលនេះនៅមិនទាន់សមស្របទៅតាមតំរូវការ *ការអភិវឌ្ឍសង្គមជាតិ*នៅឡើយ ព្រោះថាការអភិវឌ្ឍសង្គមជាតិទាមទារជាបឋមនូវពលរដ្ឋដែលមាន*ការិតជីវភាពខ្ពស់* ហើយប្រការនេះតំរូវអោយសាលារៀនអភិវឌ្ឍខ្លួនឯងបន្ថែមទៀតឆ្ពោះទៅធានា*ការកសាងវិស័យអប់រំអោយមានគុណភាពកាន់តែខ្ពស់ឡើង*។ ដើម្បីធានាបាននូវសមត្ថភាពបង្កើនការិតជីវភាពរបស់ខ្លួន នោះពលរដ្ឋម្នាក់ៗត្រូវមានសមត្ថភាពខ្ពស់ខាងការអភិវឌ្ឍខ្លួនឯងទាំងខាងចំណេះដឹង ទាំងខាងវិជ្ជាជីវៈសមស្របទៅតាមនិន្នាការអភិវឌ្ឍសង្គមដែលមានការប្រែប្រួលជាប្រចាំ។ ដើម្បីការរៀបចំពលរដ្ឋអោយឆ្លើយតបបានប្រកបដោយប្រសិទ្ធភាពទៅនឹង*ការប្រកួតប្រជែង*ក្នុងសតវត្សទី២១នេះ ទាមទារអោយសាលារៀនកសាងអោយបាននូវពលរដ្ឋដែលមានសមត្ថភាពខ្ពស់ជាង*ការសំរបសំរួល ឬភាពទន់ភ្លន់ ប្រាជ្ញាញាណ* និង*ការប៉ិនប្រសប់ លៃលកកែខៃ*។ បច្ចុប្បន្ននេះ ប្រព័ន្ធអប់រំនៅកម្ពុជាផ្តោតខ្លាំងទៅលើ*ការផ្តល់ចំណេះដឹង* មិនបានចាប់អារម្មណ៍ខ្លាំងទៅលើ*ការប្រើចំណេះដឹងនេះជាមូលដ្ឋានសំរាប់សំរបសំរួលទៅនឹងស្ថានភាពពិត ឬការប្រែប្រួលដែលនឹងមានមកជាបន្តបន្ទាប់នោះទេ* ម្ល៉ោះហើយពលរដ្ឋមួយចំនួនមានអារម្មណ៍ទុញ្ញតុះស្ទាក់ស្ទើរនៅចំពោះមុខស្ថានភាពប្លែកលំបាកអ្វីមួយ។ ស្ថានភាពនេះ ទាមទារអោយមានកំណែលំអជាចាំបាច់ ហើយកំណែលំអការអនុវត្តក្នុងបន្ទប់រៀន ជាជំហានដំបូងដែលត្រូវធ្វើ។

កន្លងមកមានការសន្មតថា មានកត្តាបីដែលជះឥទ្ធិពលលើវិស័យអប់រំ គឺ*សាលារៀន គ្រួសារ និងសង្គម*។ ការសន្មតនេះ ទន្ទឹមនឹងជួយអោយផ្នែកមួយៗបានយល់ដឹងពីសារៈសំខាន់នៃតួនាទីរបស់ខ្លួនក្នុងការធ្វើអោយវិស័យអប់រំមានការរីកចំរើននោះ ក៏បានជាលេសមួយសំរាប់ផ្នែកមួយៗធ្វើការដោះសារដែរ។ ជាញឹកញាប់ សាលារៀនធ្វើការបន្ទោសមាតាបិតាសិស្ស (គ្រួសារ) ថា មិនបានជួយ និងសហការល្អជាមួយខ្លួន។ ពួកគេច្រើនលើកឡើងថា មាតាបិតាមិនបានជួយកូនអោយរៀននៅផ្ទះ និងប្រើកូនអោយជួយការងារក្នុងគ្រួសារច្រើនពេកនាំអោយបាត់បង់ពេលវេលារៀនរបស់វា។ ទន្ទឹមនឹងនោះ គេក៏បានចោទសហគមន៍ (សង្គម) ផងដែរថា មិនបានជួយទ្រទ្រង់សាលារៀន ឬខ្វះទំនាក់ទំនងល្អជាមួយសាលារៀន។ ត្រឡប់វិញ មាតាបិតាសិស្ស (គ្រួសារ) និងសហគមន៍ (សង្គម) ក៏តែងចោទមកលើសាលារៀនវិញ ពីកង្វះប្រសិទ្ធភាពក្នុងការគ្រប់គ្រងដែលជាប្រការធ្វើអោយមានការរីកចំរើនយឺត។

ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ សន្និបាត និងការប្រជុំនានា បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើមធ្យោបាយ

កែលំអគុណភាពអប់រំ។ វាគ្មិនដែលប្រកបដោយវោហារ រមែងឡើងបញ្ចេញយោបល់យ៉ាងពីរោះ ក្បោះក្បាយ ពីមូលហេតុនានាដែលនាំអោយគុណភាពអប់រំមិនរីកចំរើន ឬរីកចំរើនតិចតួច។ ហើយជាធម្មតា គឺច្រើនជាមូលហេតុដដែលៗ និងជាមូលហេតុទាល់ច្រកមិនអាចរកដំណោះស្រាយបាន។ ជាទូទៅគេច្រើនស្តីបន្ទោសពីការិតជីវភាពទាបរបស់គ្រូបង្រៀនដែលបង្ខំអោយគាត់ត្រូវប្រកបមុខរបរទីពីរមួយទៀត ដើម្បីបំពេញក្រពះ ជាហេតុធ្វើអោយបាត់ឱកាស ក្នុងការពង្រឹងសមត្ថភាព និងបច្ចេកទេសវិជ្ជាជីវៈរបស់ខ្លួន។ ប្រការដែលប្រាក់បៀវត្សគ្រូទាបនោះ គឺជាកត្តាមួយមិនអាចទាក់ទាញ ឬរក្សាអ្នកដែលមានសមត្ថភាពអោយនៅបំរើវិស័យអប់រំឡើយ។ អ្នកខ្លះទៀតទំលាក់ កំហុសទៅលើឥទ្ធិពលអវិជ្ជមានរបស់សង្គមមានជាអាទិ៍ ល្បែងភ្នាល់ និងល្បែងកំសាន្តនានាដូចជា ខារ៉ាអូខេ ប៊ីយ៉ាជាដើម ដែលតែងទាក់ទាញកុមារអោយបោះបង់ចោលសាលារៀន។ កត្តាទីបីដែលគេច្រើនទំលាក់កំហុសទៅលើកត្តាកុមារផ្ទាល់តែម្តង។ វាគ្មិនមួយចំនួនបានស្តីបន្ទោសថា កុមារបច្ចុប្បន្ននេះ ខ្ជិលរៀន។

ពិតមែនហើយថា *សាលារៀន គ្រួសារ* និង*សង្គម* ជាកត្តាសំខាន់ដែលជះឥទ្ធិពលមកលើវិស័យអប់រំ ប៉ុន្តែកត្តាសាលារៀន គឺជា*កត្តាលេខ១*។ សាលារៀនមានតួនាទីជាកត្តាកំណត់ក្នុងការជំរុញកត្តាពីរដទៃទៀត។ ទំនាក់ទំនង និងអន្តរសកម្មភាពរវាងអ្នកពាក់ព័ន្ធទាំងឡាយក្នុងសាលារៀន គឺជាកត្តាសំខាន់សំរាប់កំណែលំអវិស័យអប់រំ។ ក្នុងបណ្តា*អ្នកពាក់ព័ន្ធ*ទាំងអស់ *នាយកសាលា*មានតួនាទីគន្លឹះក្នុងការធានា*ប្រសិទ្ធភាព*នៃអន្តរសកម្មភាព។

ការសិក្សាស្រាវជ្រាវបានបង្ហាញថា ទំនាក់ទំនងទាំងឡាយខាងក្រោមនេះមានផលប៉ះពាល់យ៉ាងធំធេងទៅលើការធ្វើអោយវិស័យអប់រំមានប្រសិទ្ធភាព :

- ទំនាក់ទំនងរវាង នាយកសាលា និងគ្រូប្រចាំថ្នាក់
- ទំនាក់ទំនងរវាង គ្រូប្រចាំថ្នាក់ និងគ្រូប្រចាំថ្នាក់
- ទំនាក់ទំនងរវាង គ្រូប្រចាំថ្នាក់ និងសិស្ស
- ទំនាក់ទំនងរវាង សិស្ស និងសិស្ស
- ទំនាក់ទំនងរវាង សាលារៀន និងមាតាបិតាសិស្ស
- ទំនាក់ទំនងរវាង សាលារៀន និងសហគមន៍។

ក្នុងទំនាក់ទំនងនីមួយៗ *ឥរិយាបថ*និង*សមត្ថភាព*របស់នាយកសាលា គឺជាកត្តាកំណត់។

(នៅមានត)

លោក អ៊ឹម សារីត់

អតីតអនុប្រធានមន្ទីរអ.យ.ក

ខេត្តតាកែវ (ចូលនិវត្តន៍)

# ភាសា

## ប្រភព : ភាសាបាលី និងភាសាសំស្ក្រឹត

ភាសាខ្មែរដែលខ្មែរយើងនិយាយ ប្រើប្រាស់សព្វថ្ងៃលាយឡំទៅដោយ "ភាសាបាលី និងសំស្ក្រឹត" រាប់ពាន់ពាក្យ។ បើពិនិត្យមើលក្នុងវចនានុក្រមខ្មែរបោះពុម្ពលើកទី៤ ឆ្នាំ១៩៦២ ភាសាបាលី និងសំស្ក្រឹត មានចំនួន៦ ៩៧៣ ពាក្យ ហើយនិងខ្ចីភាសាបរទេសមកប្រើក៏មានចំនួនច្រើនដែរ។

តើប្រភពភាសាបាលី និងសំស្ក្រឹត នេះមកពីណា?

**__បាលី__** : ប្រែថា ជួរព្រៃ រីដងព្រៃ, ស្ពាន, របៀប ភាសាមានរបៀប។ គម្ពីរពុទ្ធសាសនា គឺគម្ពីរព្រះត្រៃបិដក ដែលចារិកពុទ្ធវចនៈ សរសេរជាភាសាបាលីម្ខាង ភាសាខ្មែរម្ខាងមានចំនួន ១១០ភាគ **គឺវិន័យបិដក**១៣ភាគ **សុត្តន្តបិដក**៦៤ភាគ និង**អភិធម្មបិដក**៣៣ភាគ។ បញ្ញវ័ន្តពុទ្ធសាសនាខ្មែរ គ្រហស្ថ និងបព្វជិត ព្យាយាមបកប្រែពីភាសាបាលីមកជាភាសាខ្មែរ និងបោះពុម្ពជាសៀវភៅ ប្រើរយៈពេល៤០ឆ្នាំគត់ (១៩២៩ ដល់១៩៦៩)។

ពេលខ្លះ គេមិនថា ភាសាបាលីទេ គេថា **ភាសាមគធៈវិញ**។ **ភាសាមគធៈ** នេះចែកចេញជាពីរគឺ :

១-ភាសា សំរាប់អ្នកស្រុកនិយាយស្ដីជាធម្មតារបស់អ្នកប្រទេសមគធៈ ហៅថា **ទេសិយា**។

២-ភាសាសំដីដែលមានរបៀបទៀង ទាត់ តាមដំណើរវេយ្យាករណ៍ ជាភាសាសំរាប់ប្រើក្នុងក្បួនច្បាប់ លុះតែហាត់រៀនអោយចេះវេយ្យាករណ៍ ទើបអាចដឹង សេចក្ដីបាន ប្រើការកើត ហៅថាតន្តិ ឬតន្តិភាសា។

តន្តិ នេះជាភាសាឫសគល់របស់អ្នកមគធៈ ហៅថាបាលី ក៏បាន។ ដូច្នេះភាសាបាលី និងភាសាមគធៈ គឺតែមួយ។ **មគធៈ**នេះជាឈ្មោះដែនធំមួយនៅប្រទេសឥណ្ឌាក្នុងសម័យពុទ្ធកាល មានក្រុងរាជគ្រឹះជារាជធានី។ សព្វថ្ងៃនេះ សំដៅត្រង់ប្រទេសឥណ្ឌាដែលហៅថា "ពិហារ" ជាដែនមគធៈ ក្នុងសម័យបុរាណ។ មនុស្សរស់នៅទីនោះក៏ហៅថា **មគធៈ**ដែរ។

***__សំស្ក្រឹត__*** : ប្រែថា ពាក្យសិតសំរាំង, ភាសាសំរាំង។ សំស្ក្រឹតនេះ ជាឈ្មោះភាសាដើមដំបូងបំផុតរបស់ពួក "ហិណ្ឌូ" លុះចំណេរកាលតៗមកដរាបដល់សម័យបច្ចុប្បន្ននេះ **សំស្ក្រឹត**ប្រែក្លាយ**មតកភាសា**(ភាសាស្លាប់) ព្រោះមិនមានជនជាតិណាមួយនិយាយប្រើជាសំដីសំរាប់ជាតិរបស់ខ្លួនដោយគ្រប់គ្រាន់ឡើយ ប្រើបន្តិចបន្តួចគ្រាន់តែទុកជាមូលភាសា ឬប្រើកត់ត្រាគម្ពីរក្បួនច្បាប់ប៉ុណ្ណោះ ព្រោះភាសានេះមានរបៀបវេយ្យាករណ៍ទៀងទាត់ល្អ។ ភាសាសំស្ក្រឹតទុកដូចជា ម្ដាយ ឬបងបង្កើតនៃភាសាបាលី, របៀបវេយ្យាករណ៍ភាសាបាលីប្រើអនុលោមតាមភាសាសំស្ក្រឹតស្ទើរតែទាំងអស់។

ពាក្យសំស្ក្រឹត កាលបើមានស្រៈ **អៃ** នៅពីខាងដើមដូចជា **វៃទ្យ** ជួនណាអានឮសូរស្រៈអៃ ជួនណាអានឮសូរជាស្រៈ អេ ឬស្រៈអៃ តាមគួរដល់សូរស័ព្ទ ស្រួលមាត់ថា ដូចជាៈ **ចៃត្យ** អានថា **ចៃត្យ៍** ក៏បាន ថាចែត្យ៍ ក៏បាន។

ខ្មែរអានថា ចៃឌី ឬចៃឌី ។

ពាក្យសំស្រ្កឹតថា វៃទ្យ, ខ្មែរយើងផ្លាស់ វ ជា ព, ៃអជា អេ ឬជាអែ ផ្សំជាពេទ្យ ឬពែទ្យ ក៏បាន អានថាពែត ដូចគ្នាទាំងពីរ ។ យើងអាចសរសេរ ពេទ្យ ក៏បាន ពែទ្យ ក៏បាន តាមការពេញចិត្ត ។

ព្រោះហេតុមានវិធីអោយផ្លាស់សំលេងស្រៈ ៃអ ជា អែ បានយ៉ាងនេះហើយ បានជាបុព្វបុរសខ្មែរយើងក្នុងសម័យព្រេងនាយដែលកំពុងជក់ចិត្តជិតអារម្មណ៍ទៅរកសំដី សំស្រ្កឹតនោះ ទោះបីឃ្លាតក្លាយសំលេងខ្លះក៏ដោយ ។ លុះដល់ខ្មែរយើងត្រឡប់បែរមកកាន់ពុទ្ធសាសនា ប្រើការរៀនសូត្រតាមភាសាបាលីវិញ ក៏អានភាសាបាលីត្រង់ព្យញ្ជនៈអឃោសៈ (មូលភេទ អ) ដែលផ្សំជាមួយស្រៈ អេ ក្លាយទៅជា អែ ស្ទើរតែទាំងអស់ដូចជា : ហេតុ ស្នេហា សេព កេតុ ប្រេត ចេត្រ... អានសូរជា : ហែត ស្នែហា សែព កែត ប្រែត ចែត្រ ។ល ។

លុះមកដល់សម័យយើងដែលកន្លងផុតរាប់រយឆ្នាំហើយក្តី ក៏យើងពុំអាចកែប្រែសូរសព្ទទាំងនោះអោយឮសូរតាមប្រភពដើមឬសំណេរបានឡើយ ។ សូម្បីព្រះសង្ឃពីបុរាណ លោករៀនសូត្រធម៌ភាសាបាលីត្រង់ព្យញ្ជនៈអឃោសៈដែលផ្សំជាមួយស្រៈអេ លោកអានជាស្រៈអែ ទាំងអស់ដរាបដល់មកទសវត្សហុកសិប ហើយក្តីក៏នៅមាន ព្រះសង្ឃវត្តខ្លះ អង្គខ្លះ ប្រកាន់បុរាណ (វត្តបុរាណ លោកបុរាណ) នៅប្រកាន់សូត្រស្រៈអេ ជាស្រៈអែដែរ ។ ខ្ញុំបួសវត្តបុរាណក្នុងទសវត្សហុកសិប ។

ឧទាហរណ៍ដូចជា : ឯវម្មេ ទៅជា ឯវម្មែ, អារាមេ ទៅជាអារាមែ, អសេសតោ ទៅជាអសែសតោ, ភវន្តុតេ ទៅជាភវន្តុតែ, សត្ថេតាមេ ទៅជាសត្ថែតាមែ, ចរូបេ ទៅជាចរូបែ... ។

តាមយោបល់ខ្ញុំ ពាក្យដែលយើងខ្ចីពីបាលី សំស្រ្កឹត មកប្រើ យើងគួររក្សាទុកអំណានតាមរបៀបពីបុរាណចុះ លើកលែងតែព្រះសង្ឃ គ្រហស្ថ រៀនសូត្រធម៌ជាភាសាបាលីសុទ្ធ នោះត្រូវអានជារបៀបបាលីតាមវេយ្យាករណ៍បាលីដែលយើងមានស្រាប់ហើយ ៕

លោក អ៊ិុយ សួន

នាយកប.ថ.ស ហ៊ុន នាង ព្រែកកំពឹស

ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

**ចម្លើយៈ**

យុវជននោះទៅច្រូតស្បូវចងពីរបាច់ធំៗ រួចរែកកាត់តាមមុខផ្ទះ "តាស្វាយផ្អែម"។ មកដល់មុខតាស្វាយផ្អែម យុវជននោះពុតធ្វើចុកពោះ រួចយកបាច់ស្បូវទៅផ្ញើតាស្វាយផ្អែម ដោយបញ្ឈរស្បូវទាំង២បាច់ក្រោមដើមស្វាយផ្អែមដែលមានផ្លែទុំពេញដើម។

ស្អែកឡើង យុវជនមកសុំរែកស្បូវទៅផ្ទះ ដោយជាប់ទាំងផ្លែស្វាយទុំជ្រុះកប់ក្នុងបាច់ស្បូវទៅផង។

ដំណោះស្រាយប្រស្នាទំព័រ ២១

# ល្បែងកំសាន្ត

## ល្បែងទាយលេខបូក

នៅពេលណាមួយមិត្តអ្នកអានបានជួបជុំមិត្តភ័ក្តិ រឺបងប្អូនក្នុងពិធីអ្វីមួយ មិត្តអាចលើកយកល្បែងណាមួយមកលេងកំសាន្ត ក្នុងនោះល្បែងទាយលេខបូក ក៏អាចលេងបានដែរ ។

<u>របៀបលេង:</u> មិត្ត"ក"លេងជាមួយមិត្ត"ខ" ដោយៈ "ក" ជាអ្នកទាយ ឯ "ខ" ជាអ្នកដាក់លេខអោយ ទាយ ។ "ខ" អាចដាក់លេខប៉ុន្មានក៏បាន ហើយប៉ុន្មានខ្ទង់ក៏បាន តែដាក់ដំបូងហាមដាក់លេខ 0 និង១ នៅខាង ចុង ។ ពេល "ខ" ដាក់បានមួយជួរ "ក"ត្រូវទាយពីលទ្ធផលនៃការបូកទុកអោយហើយ ដោយដកយកចំនួន "២" ពីលេខខាងចុង មកដាក់ខាងដើម រួចចំលងលេខទាំងអស់ឡើងវិញ ដោយលេខខាងចុងទុកតែចំនួនសល់ពីដក "២" ។

<u>ឧទាហរណ៍:</u> "ខ" ដាក់ : ១៤៧៥២៨

"ក" ទាយថា : លទ្ធផលបូកចុងក្រោយគឺ ២១៤៧៥២៦

ពេល "ក" ទាយហើយត្រូវបង្វិលទៅអោយ "ខ" ដាក់លេខមួយជួរទៀតនៅជួរទី២ ។ ពេល "ខ" ដាក់ជួរទី២ រួចប្តូរមកអោយ "ក" ដាក់ជួរទី៣ រួចអោយទៅ "ខ" ដាក់ជួរទី៤ ។ ចុងក្រោយ "ក" ត្រូវដាក់ជួរទី៥ ទើបប្រគល់ទៅអោយ "ខ" បូក ។

<u>ឧទាហរណ៍:</u>

| | | |
|---|---|---|
| ខ = | ១៤៧ ៥២៨ | (ជួរទី១) |
| ខ = | ៣៦៤ ២២៧ | (ជួរទី២) |
| ក = | ៦៣៥ ៧៧២ | (ជួរទី៣) |
| ខ = | ២៥៨ ១៧0 | (ជួរទី៤) |
| ក = | ៧៤១ ៨២៩ | (ជួរទី៥) |
| | ២ ១៤៧ ៥២៦ | (លទ្ធផលចុងក្រោយ) |

***<u>កំណត់សំគាល់:</u>***

- "ក" ដាក់ជួរទី៣ និងទី៥ ដោយត្រូវដាក់លេខដែលបូកនឹងលេខរបស់ "ខ" ជួរខាងលើអោយបានស្មើនឹង ៩ ។
- ដាក់បានតែ៥ ជាន់ រឺ៥ជួរ លើស រឺខ្វះលេងមិនកើត ។
- "ក" និង "ខ" ត្រូវតែ "ខ" មិនទាន់ចេះទើបសប្បាយ ។

**លោក ឈាត់ សាំ**

# គណិតវិទ្យា

## ការស្រាវស្ទង់

- ថ្នាក់ទី ១
- មេរៀនទី ៥
- សៀវភៅសិស្សទំព័រទី ៣៣
- សៀវភៅគ្រូទំព័រទី ៣០

**<u>អត្ថបទជំនួយ :</u>**

១~ កូនចេញដំណើរពីប្រអប់លេខ [១] សំដៅទៅប្រអប់ [១២] ។ ផ្លូវដែលកូនត្រូវឆ្លងពីប្រអប់មួយទៅប្រអប់មួយនោះ គឺដើរតាមប្រអប់ដែលមានលេខបូកនឹងមួយជាបន្ត ។ មានផ្លូវពីរសំរាប់កូនអាចទៅបាន ។ ផាត់ពណ៌ផ្លូវនោះ ។




<u>ចំលើយ</u> ៖ - ផ្លូវ ១ ចេញខាងស្តាំ : ១-១២, ផ្លូវ ២ ចេញខាងឆ្វេង : ១-១២ ។

២~ តើមានសត្វចំនួនប៉ុន្មានក្នុងប្រភេទនីមួយៗ?



<u>ចំលើយ</u>៖ -  ⑤  ⑦  ③

បកប្រែដោយ កែវ យ៉ារ

CP.Objectif Calcul : cycle des apprentissages fondamentaux,p-31 (1992)



# វិធីបង្រៀនគំនូរ (ត)

ដោយលោក ប៉ាន់ ត្រា

## វិធីពិនិត្យសង្កេតរាងរៅ

ជាបឋមត្រូវអោយសិស្សអង្គុយត្រឹមត្រូវចំកន្លែងខ្លួន ហើយណែនាំអោយសិស្សមើលពិនិត្យសង្កេតលើវត្ថុគំរូ គឺដប ហើយចោទជាសំណួរដូចខាងក្រោមនេះ÷

សំណួរៈ

១- វត្ថុដែលដាក់នៅលើតុនេះគឺជាអ្វី?

២- ចូរនាំគ្នាពិនិត្យសង្កេតមើល តើដបនេះមានរាងដូចម្តេច ( មូល ឬជ្រុង)?

៣- ដបមានរាងមូល ឬមូលទ្រវែង? វែងទៅខាងណា?

៤- តាមគំហើញរបស់អ្នក ដបមានរាងរៅយ៉ាងណា? (សំណួរទី ៤ នេះ ត្រូវចោទសួរសិស្សដែលអង្គុយនៅកន្លែងខុស១គ្នាក្នុងបន្ទប់រៀនអោយបានច្រើននាក់ ដើម្បីបញ្ជាក់គំហើញរបស់ខ្លួន) ។

៥- ដូចនេះគំហើញរបស់មិត្តរបស់អ្នកទាំងអស់ដូចគ្នាដែរឬទេ?

៦- ហេតុនេះ វត្ថុដែលមានរាងមូល ហើយវែងទៅលើដូចដបនេះ អាចផ្លាស់ប្តូររាងរៅទៅតាមទីកន្លែង និងទិសរបស់អ្នកមើលដែរឬទេ?

៧- ចូរអ្នករិះរកមើលវត្ថុណាខ្លះដែលមានរាងមូល ហើយវែងទៅលើដូចដបនេះ?

៨- ដូចនេះវត្ថុដែលមានរាងមូល ហើយវែងទៅលើដូចដបនេះ ត្រូវមើលឃើញប្លែក១គ្នា ឬខុសគ្នា?

## វិធីវាស់ប្រមាណទទឹង និងបណ្តោយ

ដោយសិស្សពុំទាន់ដឹងសោះនៅឡើយអំពីវិធីវាស់ប្រមាណនេះ សូមលោកគ្រូ អ្នកគ្រូវាស់ជាឧទាហរណ៍ដោយមានការពន្យល់អោយបានច្បាស់លាស់ដល់សិស្ស ។

ដើម្បីវាស់ប្រមាណអោយដឹង ទទឹង ឬកំពស់វត្ថុផ្សេង១ ត្រូវប្រើវិធីដូចខាងក្រោមនេះ ។

**វិធីវាស់ទទឹង**

១- ដៃស្តាំកាន់ខ្មៅដៃផ្តេក ដោយបញ្ចេញមួយភាគនៃខ្មៅដៃនោះទៅឆ្វេង ។

២- សន្ធឹងដៃត្រង់ទៅមុខអោយអស់ត្រឹមទៅដប ។

៣- បិទភ្នែកឆ្វេង ហើយភ្នែកស្តាំសំលឹងមើលអោយចំផ្នែកខ្មៅដៃ ផ្ទួរទៅនឹងទទឹងដប ។

៤- ចំណែកខ្មៅដៃដែលលូតទៅឆ្វេងនោះ ត្រូវមានប្រវែងស្មើនឹងទទឹងដប ដោយបង្អិតមេដៃទៅឆ្វេង ឬទៅស្តាំ លុះត្រាតែផ្នែកខ្មៅដៃនោះ និងទទឹងដបមើលទៅឃើញប្រវែងគ្នា ។

**គំនូរពន្យល់របៀបវាស់ (របស់មានរាងមូលវែង)**



រូបទី១

៥- លុះវាស់ខ្នាតទទឹងហើយ ត្រូវគូសគំនូសផ្ដេកមួយនៅផ្នែកខាងក្រោមចំកណ្ដាលផ្ទៃក្រដាស គឺបាតដបដោយមានបន្ទាត់សូន្យពុះ ចំកណ្ដាល (រូបទី១) ។ (គំនូសផ្ដេកនេះ ត្រូវគូសលៃតាមចិត្តយើងចង់បានដោយយោងទៅតាមទំហំផ្ទៃក្រដាសដែលយកមកគូរ) ។



រូបទី២

៦- យកខ្នាតទទឹង ទៅវាស់ផ្ទួរនឹងកំពស់ដប ដើម្បីអោយដឹងថា តើកំពស់ដបនេះ មានប៉ុន្មានខ្នាតទទឹង (ចំពោះដបនេះ ដូចគំនូរនេះបង្ហាញស្រាប់ គឺទទឹង៣ដង ទើបស្មើនឹងកំពស់) ។

៧- យកខ្នាតទទឹងដែលគូសនៅបាតដបនោះ ទៅវាស់លើផ្ទៃក្រដាសតាមបន្ទាត់សូន្យ ពីបាតក្រោមទៅលើ៣ខ្នាតទទឹង ហើយចុចជាចំណុចសំគាល់ផង (រូបទី២) ។

៨- នៅចំណុចខាងលើបំផុតគឺមាត់ដបត្រូវគូសគំនូសផ្ដេកមួយទៀតប្រវែងស្មើនឹងបន្ទាត់ខាងក្រោម(រូបទី៣)



រូបទី៣

៩- គូសគំនូសត្រង់បញ្ឈរពីរ ភ្ជាប់ចុងគំនូសបាត និងមាត់ (យើងបានជាចតុកោណកែងមួយដែលមានទទឹងស្មើនឹងទទឹងដប និងបណ្ដោយស្មើនឹងកំពស់ដប)(រូប ទី៣) ។

១០- យកខ្នាតទទឹងទៅវាស់ប្រមាណកំពស់ដប ដើម្បីអោយដឹងថា តើកដបនោះ បើផ្ទួរទៅនឹងខ្នាតទទឹង តើវែង ឬខ្លីជាង (ចំពោះកដបដែលគូរជាឧទាហរណ៍នេះ មានកំពស់ស្មើនឹងទទឹង គឺ១/៣ នៃកំពស់ដប) ។



រូបទី៤

១១- ត្រូវគូរកដបនេះលើក្រដាសក្នុងភាគខាងលើរបស់ចតុកោណកែងនោះ (រូបទី៤) ។

គំនូរទាំងអស់ដែលបានគូររួចមកហើយនោះ យើងគ្រាន់តែគូសជាគំនូសបង្ហាញតែរាងរៅប៉ុណ្ណោះ ។ ដូចនេះគំនូរទាំងនោះពុំទាន់មានលក្ខណៈច្បាស់លាស់នៅឡើយទេ ។ ដើម្បីអោយគំនូរទាំងនោះ បញ្ជាក់រូបរាងខ្លួនអោយបានរឹតតែច្បាស់លាស់ជាក់ស្ដែងនោះ យើងត្រូវអោយស្រមោលគំនូរនោះថែមទៀតដូចគំនូរជាឧទាហរណ៍ខាងក្រោមនេះ ។

## ការអោយស្រមោលវត្ថុមានរាងមូលវែង

### ពន្លឺបាំងចំពីចំហៀង




បំពង់




ពាងស្ករ




ជើងផ្កា

<u>ការពិនិត្យសង្កេត</u>

ចូរពិនិត្យមើលគំនូរខាងលើនេះយើងនឹងឃើញច្បាស់ថា ÷

- ផ្នែកបំពង់ ខាប់ស្គរ និងជើងផ្កា ដែលត្រូវពន្លឺចាំងមកចំ គឺផ្នែកខាងឆ្វេង មានសម្បុរភ្លឺ ( ខ្ចី ) ។
- ផ្នែកដែលត្រូវបាំងពន្លឺ គឺផ្នែកខាងស្តាំ មានសម្បុរងងឹត ។

<u>របៀបដាក់ស្រមោល</u>

- ត្រូវដាក់ស្រមោលងងឹត ( ខ្មៅ ) នៅចំហៀងខាងស្តាំដែលបាំងពន្លឺ ។
- ស្រមោលងងឹត( ខ្មៅ )នោះ ត្រូវប្រែពណ៌ទៅជាខ្ចីបន្តិចម្តងៗ កាលណាស្រមោលនោះខិតមកកណ្តាល លុះត្រាតែរលុបបាត់ ។

<u>ពន្លឺចាំងចំពីមុខ</u>

កាលណាពន្លឺចាំងចំពីមុខ ត្រូវអោយស្រមោលដូចគំនូរជាឧទាហរណ៍ខាងក្រោមនេះ ÷




<u>ការពិនិត្យសង្កេត</u>

ចូរសង្កេតពិនិត្យមើលរបៀបអោយស្រមោលគំនូរខាងលើនេះ យើងនឹងឃើញជាក់ថា ÷

- ផ្នែកបំពង់ ខាប់ស្គរ និងជើងផ្កា ផ្នែកខាងមុខដែលត្រូវពន្លឺចាំងមកចំមានសម្បុរ ( ខ្ចី ) ។
- ផ្នែកចំហៀងទាំងពីរខាង គឺចំហៀងខាងស្តាំ និងខាងឆ្វេង មានសម្បុរងងឹត ។

<u>របៀបដាក់ស្រមោល</u>

- ត្រូវអោយស្រមោលងងឹតផ្នែកបំពង់ ខាប់ និងជើងផ្កា ទាំងពីរខាង ។
- ស្រមោលងងឹតខ្មៅនោះ ត្រូវប្រែសម្បុរទៅជាខ្ចីបន្តិចម្តងៗ ហើយរលាយបាត់កាលមកដល់កណ្តាល ។

( នៅមានត )




# ការអប់រំក្នុងគ្រួសារ

(បទព្រហ្មគីតិ)

ប្រពន្ធប្ដី និងកូន ភាពរលូនមានជាអាទិ៍ មានធមិអប្បមាទ
ហើយឱហាត(១) រួមដៃធ្វើ ។
មេផ្ទះដែលឆ្លាតឈ្លាស ត្រូវរវៀសសព្វសារពើ កូនចៅបង្រៀនធ្វើ
កុំគ្រាន់បើធ្វើតែឯង ។
កុំធ្វើស្រេចនឹងចិត្ត ប្រើគំនិតគិតបែកឆ្វេង គួរប្រើក្សាកុំរើងង
ចង់ឈ្នះលែងបានក្ដីសុខ ។
ប្ដីប្រពន្ធត្រូវយក ហេតុផលមកដោះបន្ទុក កុំអាងខ្លួនប្រមុខ
រួមសុខទុក្ខកុំបែរខ្នង ។
ត្រូវគ្រប់គ្រងចំណង់ ដោយស្មោះត្រង់ស្រាយចំណង មុនធ្វើគួរគិតផង
ត្រូវគ្រប់គ្រងចិត្តបញ្ញា ។
បើមានរឿងរង្កៀស ត្រូវវៃឈ្លាសកុំអាលថា ត្រូវគិតពិចារណា
ទើបគ្រួសារបានសុខអើយ ៕

លោក ឆេព សាធន

---

(១) ឧស្សាហ៍ ព្យាយាម

# សម្បទាសាវិទ ៤

(បទពាក្យ ៧)

មនុស្សយើងរាល់រូបលើលោកា ត្រូវតែឧស្សាហ៍ខំត្រងត្រាប់ ចាប់យកព្រះធម៌ដែលជាច្បាប់
ត្រូសត្រាយហើយស្រាប់សំរាប់រស់ ។
ទីមួយឧដ្ឋានសម្បទា រាល់ពេលគ្រប់គ្រាត្រូវតែរូស[១] ប្រកបកិច្ចការមិនច្រអូស
ទើបយើងសមរស់តាមពុទ្ធឱវាទ ។
ទីពីរអារក្សសម្បទា យើងរាល់រូបាត្រូវសង្វាត យកចិត្តទុកដាក់មិនប្រមាថ
ថែទាំឱ្យហាតមិនខ្ចះខ្ចាយ ។
ទីបីកល្យាណមិត្តា ត្រូវគប់[២] មិត្តណាដែលរួសរាយ រាក់ទាក់ជួយយើងទាំងសម្ចាយ
មានចិត្តខ្វល់ខ្វាយមិនរើសអើង ។
ទីបួនសមជីវិតា ចាយវាយទ្រព្យាមិនទំនើង មិនអោយហួសហេតុមិនជំកើង
យសសក្ដិផងយើងមិនសមសួន ។
ប្រការទាំងបួនត្រូវចងចាំ មិនមើលបំណាំយកជាក្បួន អនុវត្តអោយជាប់ជាក់ក្នុងខ្លួន
ទុកដាក់ថែថ្នមយើងបានសុខ ៕

លោក ចែត សិន

គ្រូបង្រៀនចូលនិវត្តន៍

"ស្ងួវស្ងួចកុំអោយដាច់ បើវាតិចអោយឧស្សាហ៍
រិះរកផ្សំទៀតណា អោយបានច្រើនក្របើនទុក ។
នឹងចាយអោយគិតក្រោយ ទោះនឹងអោយ អោយមើលមុខ
កុំអោយស៊ីកគ្រលុក ទោះនឹងទុកអោយចំណាំ ។
រង្វើរធ្វើចំការ អោយឧស្សាហ៍គ្រៀងគ្រាប់ដាំ
ស្ទីកគ្រៃឱ្យគ្រប់ត្រុំ គ្រាវគ្រសក់សព្វបន្លែ ។"

ច្បាប់ប្រុស

(១) រួស (គុណនាម ឬកិរិ) : រហ័ស, ឆាប់ ។ (២) គប់ (កិ): រាប់រកគ្នា, ចងសមាគមនឹងគ្នា ។

# ទិដ្ឋភាពស្រុកស្រែពេលខែវស្សា

(បទពាក្យ ៧)

ពិសាខដើមឆ្នាំភ្លៀងជោគដី　　រុក្ខជាតិលាស់ខ្ចីស្រស់បំព្រង
បៃតងស្រងាត់ល្អកន្លង　　តាមព្រៃភ្នំផងគួរគយគន់ ។
ក្នុងស្រែមានទឹកពេញល្អល្ងាច　　ហួរហៀរបាចសាចលិចជោរជន់
កសិករប្រុសស្រីមិនទម្រន់　　ទូលរែកលីពុនជីដាក់ស្រែ ។
ចាប់ផ្ដើមភ្ជួរដាស់ដីបណ្ដើរ　　ចិត្តមិនស្ទាក់ស្ទើរឬទំនេរ
ធ្វើថ្នាលព្រោចពូជសាបហួរហែ　　លើកទប់ភ្លឺស្រែថែទាំទឹក ។
សំណាបដល់ខែប្រែភ្ជួរដី　　រាស់កិនលកលៃឆ្នៃពេលព្រឹក
ល្ងាចដកព្រឹកស្ទូងមិនព្រួយនឹក　　អោយតែមានទឹកធ្វើរហូត ។
ខែនេះនៅវាលពេញដោយមនុស្ស　　ក្មេងចាស់ស្រីប្រុសឃើញរកូត
សំលេងអួអរស្នូរតមាត់　　មនុស្សហើយនិងសត្វសប្បាយម្លេះ ។
ចប់ការដកស្ទូងខំប្រឹងថែ　　លើភ្លឺក្នុងស្រែមិនប្រហែស
បាចជីបាញ់ថ្នាំស្មៅបោចបេះ　　ទៅតាមតំរិះបទពិសោធន៍ ។
សន្ទូងបែកគុម្ពធំក្រអូប　　ក្លិនគួរចង់ស្រូបក្រោមម្លប់ត្នោត
បន្ធូរអារម្មណ៍ដែលចាក់ដោត　　អោយបានស្បើយផុតទុក្ខកង្វល់ ។
ស្រែណាក៏ដូចស្រែណាដែរ　　ពណ៌ខៀវដូចព្រៃពេលត្រូវខ្យល់
រលកអង្កាញ់បាញ់វិលវល់　　ស្រែទាបស្រែទួលល្អដូចគ្នា ។
ទាំងនេះគឺជាការខំប្រឹង　　អស់ពីកម្លាំងកាយប្រាថ្នា
មិនខ្លាចព្យុះភ្លៀងខ្យល់រងា　　តស៊ូពុះពារឥតរាឡើយ ។
គ្រប់គ្នាមានទឹកមុខញញឹម　　ដោយក្ដីសង្ឃឹមទៅថ្ងៃក្រោយ
ជីវភាពពួកគេបានធូរស្បើយ　　នៅពេលនេះហើយដែលសប្បាយ ៕

លោក ហាស់ ម៉ុចតេវ៉ា
អធិការបឋមសិក្សា
មន្ទីរអ.យ.ក ខេត្តស្វាយរៀង

# ជំនឿរបស់ខ្មែរលើរូប "ទីងមោង"

រូបទីងមោងពីដើមមកគេធ្វើសំរាប់ដាក់នៅវាលស្រែចំការ ដើម្បីបង្អើលសត្វបក្សាបក្សី ឬសត្វព្រៃដែលចូលមកស៊ីផលដំណាំរបស់អ្នកស្រុក ប៉ុន្តែឥឡូវនេះត្រូវបានប្រជាជនខ្មែរយើងខ្លះ និងនៅតាមតំបន់ខ្លះនៃប្រទេសកម្ពុជាបែរត្រឡប់ធ្វើរូបទីងមោងនេះ យកមកដាក់នៅមុខផ្ទះរបស់ខ្លួនដោយមានជំនឿ និងយល់ថាជាគ្រឿងការពារភយន្តរាយផ្សេងៗ។

ខ្មែរយើងធ្លាប់និយាយថា មនុស្សនេះស្ងៀកពាក់មើលតែទីងមោង! ឬនិយាយថា មនុស្សនេះមិនមានឧបាយកលអ្វីដោះស្រាយបញ្ហានៅថ្មឹងដូចទីងមោងអញ្ចឹង!។

**អ្វីទៅ ទីងមោង?**

តាមោង ឬទីងមោង (ន) ភាសាព្នងថា ទីងម៉ូង = "ខ្លា" ពាក្យនេះកាលពីជំនាន់ខ្មែរ ប្រើជនជាតិព្នងជាទាសកម្មករអោយថែរក្សាផ្ទះ ទ្រព្យសម្បត្តិ មើលថែរក្សាកូនក្មេង កាលណាក្មេងយំកិកកុក ជនជាតិព្នងដែលថែរក្សាក្មេងនិយាយបន្លាចថា "ទីងម៉ូងៗ" ដើម្បីអោយក្មេងខ្លាចលែងយំ ដូចជានិយាយបន្លាចថា កុំយំប្រយ័ត្នទីងមោងខាំ!។ ពាក្យទីងមោង ក៏មានជាប់តាំងពីពេលហ្នឹងមក។ លុះគ្រាក្រោយមក ខ្មែរយើងប្រើហៅរូប ដែលគេរុំសំពត់ខោអាវចាស់ៗ ដែលធ្វើជារូបមនុស្សដាក់បញ្ឈរក្នុងស្រែចំការ ដើម្បីបន្លាចសត្វមិនអោយចុះ ឬចូលស៊ីផលដំណាំថា តាមោង ឬទីងមោង។ (វចនានុក្រមខ្មែរទំព័រ ៣៨៣)។

នៅមានរឿងព្រេងមួយទៀតបាននិយាយពីទីងមោងនេះដែរ។ មានសេចក្តីតំណាលថា: កាលពីព្រេងនាយមានក្មេងប្រុសពីរនាក់ជាកូនភ្លោះ បងឈ្មោះទីង ប្អូនឈ្មោះមោង កំព្រាឪពុកម្តាយតាំងពីតូច។ កុមារទាំងពីររស់នៅជាមួយជីដូនជីតាក្បែរភ្នំមួយ។

យាយ និងតាមានមុខរបរជាអ្នកធ្វើស្រែផង ចំការផង។ ផ្ទះរបស់គាត់នៅដាច់ឆ្ងាយពីផ្ទះគេឯង។ លោកយាយលោកតាជាអ្នកប្រកាន់ខ្ជាប់នូវព្រះពុទ្ធសាសនា តែងនាំគ្នាទៅវត្ត សមាទានសីលរៀងរាល់ថ្ងៃសីលពុំដែលខានឡើយ ហើយអោយចៅទាំងពីរនាក់នៅចាំផ្ទះ និងការពារផលដំណាំក្នុងស្រែចំការ។

ផលដំណាំរបស់លោកយាយ និងលោកតា មានផ្លែផ្កាស្លេកស្លុះជារៀងរាល់រដូវ ប៉ុន្តែការប្រមូលផលពុំបានគាប់ចិត្តឡើយ ព្រោះហ្វូងសត្វព្រៃមកស៊ីបំផ្លាញពុំកោតក្រែងសោះ ស្ទើរពុំមានសល់។

ថ្ងៃសីលមួយពេលយាយតាទៅវត្ត ចៅទីង ចៅមោង នាំគ្នាធ្វើគ្រឿងប្រហារ ដើម្បីការពារផលដំណាំ គឺធ្វើធ្នូ និងស្នាទុកសំរាប់បាញ់សត្វស្លាប ជ្រូកព្រៃ និងសត្វដទៃទៀត។ ធ្វើរួចស្រេចហើយ នាំគ្នាទាំងពីរនាក់បងប្អូនសំដៅមកចំការដំណាំ ដើរមកដល់ពាក់កណ្តាលផ្លូវ ស្រាប់តែជួបយាយតា ត្រឡប់មកពីវត្តវិញ។ លោកតាទូន្មានចៅទាំងពីរថា គ្រឿងអាវុធរបស់ចៅនេះមិនមែនជាគ្រឿងការពារផលដំណាំបានស្ថេរភាពទេ តែកាលណាម្ចាស់ដេក វាក៏ដេកដែរ។

ម្យ៉ាងទៀត វាជាគ្រឿងសាងអំពើបាបផង! អញ្ជើញទេចូរចៅត្រឡប់ទៅផ្ទះវិញ។ អ្នកទាំងពីរតាមយាយតាទៅផ្ទះវិញទាំងខកចិត្ត។

ថ្ងៃសីលក្រោយទៀត ឆ្លៀតពេលយាយតាមិននៅ ចៅទាំងពីរគិតឃើញពីល្បិចការពារផលដំណាំដោយប្រើវិធីថ្មី គឺយកឆ្នាំងដីមកចោះរន្ធពីរ ធ្វើភ្នែក រួចយកកំបោរស លាយទឹកសើមៗ ផ្តិមគូរមុខក្រវេមក្រវាម ដាមពណ៌ជាប់លើឆ្នាំងចាំងសខ្មៅ ដៅបានជាមុខយក្ស ហើយលើកពាក់លើក្បាលចៅមោង។ ចៅទីងអង្គុយ ហើយអោយចៅមោងឡើងជិះច្រកកៀវពីលើស្មារបស់ខ្លួន។ អ្នកទាំងពីរបានយកចំបើងមកចងរុំជើងដៃ ច្នៃបានជារូបមួយលែង មើលស្គាល់ថា ជាមនុស្ស។ រួចហើយវាក៏យកអាវខ្មៅបំពង់វែង រហែកដែលយាយបោះបង់ចោលមកពាក់ពីលើរហូតដល់ក្រោម មើលទៅដូចជាសត្វចំលែកមួយយ៉ាងធំគួរអោយខ្លាច។ អ្នកទាំងពីរដើរឆ្ពោះទៅចំការ ព្រមទាំងបន្លឺសំលេងគ្រលរៗថា "ទីងមោង!ៗ"។ ហ្វូងសត្វទ្វេបាទ និងចតុប្បាទ គ្រាន់តែក្រឡេកឃើញភ្លាម ក៏ផ្អើលឆោឡោ ខ្លះហើរ ខ្លះរត់បោល តែរៀងៗខ្លួនទៅពួននៅឯព្រៃជ្រៅ លែងហ៊ានមកក្បែរចំការជារៀងរហូត។ ក្រោយមកផលដំណាំក៏គង់វង្សផ្លែផ្កាបរិភោគលែងខ្វះដូចមុនឡើយ។

ដំណឹងនេះដឹងដល់អ្នកជិតខាង គេក៏នាំគ្នាយកតំរាប់តាម គឺគេធ្វើរូបសំណាកចៅ "ទីងមោង" ដាក់បង្អើលសត្វនៅតាមស្រែចំការរបស់ពួកគេគ្រប់ៗគ្នា។ លុះយូរៗទៅក៏ដឹងដល់ប្រជាកសិករទូទាំងនគរ ក៏នាំគ្នាធ្វើតៗរៀងមក។ ដូចនេះហើយ ទើបខ្មែរយើងហៅរូបទាំងនោះថា "ទីងមោង" តាំងពីពេលនោះមករហូតសព្វថ្ងៃនេះ។

រឿងរ៉ាវដែលខ្ញុំបានរៀបរាប់ និងការស្រាវជ្រាវរបស់ខ្ញុំ មកជំរាបជូននេះ ទុកជាចំណេះដឹងទូទៅ សំរាប់វិភាគពិចារណាថា : "តើជំនឿលើរូបទីងមោងនេះ វាមានឥទ្ធិពលអ្វី ឬសមហេតុផលអ្វីដែរ ដែលអាចយកជាគតិបាន?"។.

លោក អ៊ុយ សួន

នាយកប.ឋ.សហ៊ុន នាង ព្រែកកំពឹស

ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

**ការកត់សំគាល់នាមផ្សេងៗរបស់ព្រះពុទ្ធ**

- សិទ្ធត្ថ (សិទ្ធាថ៌) - នាមពីកំណើត- អ្នកសំរេចប្រយោជន៍បានតាមបំណង។
- គោតម - នាមត្រកូលរបស់ព្រះពុទ្ធ ព្រោះព្រះអង្គជាគោតមគោត្ត។
- សក្យ ឬសាក្យ - បណ្ឌិតដែលប្រសូតចេញពីត្រកូលសក្យ (ជនពូជមួយនៅក្នុងដែនសក្កៈ)។
- តគវត ឬភគវន្ត - អ្នកដែលមានជោគ មានបុណ្យ។
- តថាគត (តថ + អាគត) - អ្នកដែលបានសំរេច គឺសុក្រិត។
- ជិនៈ - អ្នកដែលទទួលជ័យជំនះ។
- លោកវិទូ - អ្នកបានជ្រាបច្បាស់នូវលោក។
- ព្រះពុទ្ធ - អ្នកដែលបានត្រាស់។



## បំបាត់ការឈឺចាប់ដោយខ្លួនឯង

រហូតដល់សព្វថ្ងៃនេះ យើងក៏នៅឃើញមានការព្យាបាលបែបបូរាណមួយ នោះគឺការចាប់ ការកាយសរសៃ រឺការអុច។ ប្រការនេះ មិនខុសអ្វីពីការចាក់ម្ជុលវិទ្យាសាស្ត្របែបបូរាណចិន ហើយនិងរូបភាពបែបទំនើប គឺម៉ាស្សាការឈ្លី រឺស្ទំដោយឧបករណ៍ប្រើអគ្គីសនី (រូបខាងក្រោម)។




ដើម្បីចាប់ កាយសរសៃ ឬអុច គេច្រើនកំណត់យកចំណុចតូចនៃរាងកាយយើង សមស្របនឹងការឈឺចាប់ដោយ÷

- ដំបូងត្រូវស្រាវជ្រាវរកចំណុចសមស្របនោះ។ កាលបើយើងចុចចំចំណុចនោះ នោះវាអួលជាងគេ។
- បន្ទាប់មក យើងត្រូវឈ្លីចំចំណុចនោះ ទោះបីវាមានការឈឺចាប់ខ្លាំងក៏ដោយ ត្រូវឈ្លីចុងម្រាមដៃតាមទំរង់ទ្រនិចនាឡិកា រយៈពេល២ ឬ៣នាទី រហូតដល់ពេលបាត់ការឈឺចាប់។



ចំណុចនៃការចុកអួលមាននៅទីកន្លែងផ្សេងៗរបស់សរីរាង្គកាយយើងពាក់ព័ន្ធនឹងការឈឺចាប់ដែលគេអាចកត់សំគាល់ដូចតទៅ ÷

**ការហើមហាល់** : ការហើមហាល់នេះផ្សារភ្ជាប់ទៅនឹងការរីកប៉ោងហោប៉ៅខ្យល់របស់ក្រពះ។ ជាទូទៅ គេកត់សំគាល់ឃើញថា ខ្យល់ដែលដកចូលមិនអាចឆ្លងទៅដល់ក្រពះទេ វាចូលដល់ក្នុងសួត រួចចេញមកវិញ។ ម្យ៉ាងទៀត ការហើមហាល់ គឺជាសញ្ញាមួយនៃការឈឺក្រពះ រីគ្រួសក្នុងប្រមាត់។ ក្នុងករណីឈឺចាប់នេះ គេកត់សំគាល់ឃើញកន្លែងត្រូវឈ្លីមានពីរ ÷





**ការចុចចាប់ឆ្អឹងខ្នង**

**ការឈឺចាប់ទ្វារធំ**





**ការសំរាន្តមិនលក់ : ក្នុងករណីនេះ គេចាប់ច្របាច់២កន្លែងយ៉ាងយឺតៗ មួយៗ÷**

ទី១



ទី២



## ការចុកចាប់កំភួនជើង



ប្រែសំរួលដោយ តែង យ៉ារ




# តើលោកគ្រូ អ្នកគ្រូដឹងដែរឬទេថា...
## អំពីតំបន់ការពារធម្មជាតិ

ដើម្បីរួមចំណែកការពារបរិស្ថាន នៃធម្មជាតិពិភពលោកអោយនៅគង់វង្ស សំរាប់ជាប្រយោជន៍ដល់មនុស្សដែលមានចំនួនកើនឡើងយ៉ាងខ្លាំងក្លាឥតឈប់ឈរអោយអាចរស់នៅលើផែនដីនេះបានតទៅទៀតនោះ ប្រទេសកម្ពុជាយើងក៏បានបង្កើត និងកំណត់តំបន់ការពារធម្មជាតិ(១) ទៅតាមប្រព័ន្ធអេកូឡូស៊ី ដី ព្រៃឈើ តំបន់សើម និងតំបន់ឆ្នេរទៅតាមប្រភេទធំៗ ៤ យ៉ាងដូចតទៅ ÷

**១-ឧទ្យានជាតិ** : គឺដែនធម្មជាតិ និងទស្សនីយភាពដែលត្រូវការពារ ដើម្បីបំរើអោយវិទ្យាសាស្ត្រ ការអប់រំ និងការកំសាន្ត ។

**២-ដែនជំរកសត្វព្រៃ** : គឺដែនធម្មជាតិដែលធានានូវលក្ខខណ្ឌធម្មជាតិ ចាំបាច់ក្នុងការការពារប្រភេទសត្វព្រៃ និងរុក្ខជាតិរបស់ជាតិសំខាន់ៗ និងសហគមន៍ធម្មជាតិ ឬលក្ខណៈរូបសាស្ត្ររបស់បរិស្ថាន ជាទីដែលភាវៈទាំងនេះត្រូវការ ជាពិសេសនូវអន្តរាគមន៍ពីមនុស្សសំរាប់ការស្ថិតស្ថេររបស់វា ។

**៣-តំបន់ការពារទេសភាព** : គឺតំបន់ដែលត្រូវថែទាំងទេសភាពធម្មជាតិ និងពាក់កណ្តាលធម្មជាតិសំខាន់ៗសំរាប់រមណីយដ្ឋានដល់សាធារណជនក្នុងការសំរាកកំសាន្ត និងធ្វើទេសចរណ៍ ។

**៤-តំបន់ដែលទទួលរងនូវការប្រើប្រាស់ច្រើនយ៉ាង** : គឺតំបន់ដែលផ្តល់នូវភាពស្ថិតស្ថេរលើប្រភពទឹក ព្រៃឈើ សត្វព្រៃ ត្រី វាលស្មៅ និងការកំសាន្តដោយតំរូវអោយមានការអភិវឌ្ឍន៍អភិរក្សធម្មជាតិក្នុងគោលដៅចំបងនៃសកម្មភាពសេដ្ឋកិច្ច ។

| ឧទ្យានជាតិ | ផ្ទៃដី "ហ.ត" | ទីតាំង | ៤-រាម | ១៥ ០០០ | ក្រុងព្រះសីហនុ |
|---|---|---|---|---|---|
| ១- ខ្ចង់រាបគីរីរម្យ | ៣៥ ០០០ | ខេត្តកំពង់ស្ពឺ និងកោះកុង | ៥- បូទុមសាគរ | ១៧១ ២៥០ | ខេត្តកោះកុង |
| ២- ភ្នំបូកគោ | ១៤០ ០០០ | ខេត្តកំពត | ៦- ភ្នំគូលែន | ៣៧ ៥០០ | ខេត្តសៀមរាប |
| ៣- កែប | ៥ ០០០ | ខេត្តកំពត | ៧- វីរជ័យ | ៣៣២ ៥០០ | ខេត្តស្ទឹងត្រែង និងរតនគីរី |

(១) ព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣

| ដែនជម្រកសត្វព្រៃ | ផ្ទៃដី "ហ.ត" | ទីតាំង |
|---|---|---|
| ៨- ភ្នំឱរ៉ាល់ | ២៥៣ ៧៥០ | ខេត្តកោះកុង ពោធិសាត់ កំពង់ឆ្នាំង |
| ៩- ពាមក្រសោប | ២៣ ៧៥០ | ខេត្តកោះកុង |
| ១០- ភ្នំសំកុស | ៣៣៣ ៧៥០ | ខេត្តកោះកុង |
| ១១- រនាមដូនស់ | ១៧៨ ៧៥០ | ខេត្តបាត់ដំបង |
| ១២- គូលែន-ព្រហ្មទេព | ៤០២ ៥០០ | ខេត្តសៀមរាប និងព្រះវិហារ |
| ១៣- បឹងពែរ | ២៤២ ៥០០ | ខេត្តកំពង់ធំ |
| ១៤- លំផាត់ | ២៥០ ០០០ | ខេត្តរតនគិរី និងមណ្ឌលគិរី |
| ១៥- ភ្នំព្រេច | ២២២ ៥០០ | ខេត្តមណ្ឌលគិរី និងក្រចេះ |
| ១៦- ភ្នំណាមលៀវ | ៤៧ ៥០០ | ខេត្តមណ្ឌលគិរី |
| ១៧- ស្នួល | ៧៥ ០០០ | ខេត្តក្រចេះ |
| **តំបន់ការពារទេសភាព** | **ផ្ទៃដី "ហ.ត"** | **ទីតាំង** |
| ១៨- អង្គរ | ១០ ៨០០ | ខេត្តសៀមរាប |
| ១៩- បន្ទាយឆ្មារ | ៤១ ២០០ | ខេត្តបន្ទាយមានជ័យ |
| ២០- ព្រះវិហារ | ៥ ០០០ | ខេត្តព្រះវិហារ |
| **តំបន់ប្រើប្រាស់ច្រើនយ៉ាង** | **ផ្ទៃដី "ហ.ត"** | **ទីតាំង** |
| ២១- ដងពែង | ២៧ ៧០០ | ខេត្តកោះកុង |
| ២២- សំឡូត | ៦០ ០០០ | ខេត្តបាត់ដំបង |
| ២៣- ទន្លេសាប | ៣១៦ ២៥០ | ខេត្តកំពង់ឆ្នាំង, កំពង់ធំ, សៀមរាប, បាត់ដំបង និងពោធិសាត់ |




ព្រំប្រទល់នៃតំបន់ការពារធម្មជាតិនីមួយៗ

ក្នុងចំណោមតំបន់ការពារធម្មជាតិទាំង ២៣ កន្លែងនេះ តំបន់ទន្លេសាបបានចូលជាឋានីយជីវមណ្ឌលនៃពិភពលោក កាលពីឆ្នាំ១៩៩៧។

# បុគ្គលិកអប់រំនៅមន្ទីរអប់រំខេត្ត/ក្រុង, ការិយាល័យអប់រំស្រុក/ខណ្ឌ និងសាលារៀន ឆ្នាំសិក្សា២០០៤-០៥

| ខេត្ត-ក្រុង | ប្រធានមន្ទីរអប់រំ ខេត្ត-ក្រុង | មន្ទីរអប់រំ ខេត្ត/ក្រុង | | ការិ.អប់រំ ស្រុក/ខណ្ឌ | | បុ.បង្រៀនក្នុង សាលារៀន | | បុ.មិនបង្រៀន ក្នុងសាលារៀន | | បុគ្គលិកសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| បន្ទាយមានជ័យ | លោក ប្លុង សារុត | 56 | 14 | 102 | 14 | 3.744 | 1.414 | 707 | 117 | 4.609 | 1.559 |
| បាត់ដំបង | លោក ម៉ៅ ម៉ុ | 109 | 26 | 156 | 31 | 5.980 | 2.941 | 1.281 | 320 | 7.526 | 3.318 |
| កំពង់ចាម | លោក ហួត ឧន់ | 113 | 27 | 174 | 37 | 8.998 | 3.854 | 2.113 | 513 | 11.398 | 4.431 |
| កំពង់ឆ្នាំង | លោកស្រី ផាត់ ធនី | 76 | 29 | 86 | 18 | 2.623 | 879 | 540 | 142 | 3.325 | 1.068 |
| កំពង់ស្ពឺ | លោក សំ សមន្ថា | 61 | 9 | 96 | 13 | 3.742 | 1.116 | 896 | 146 | 4.795 | 1.284 |
| កំពង់ធំ | លោក ស៊ូ គីមទ្រី | 60 | 10 | 85 | 17 | 3.727 | 1.494 | 574 | 103 | 4.446 | 1.624 |
| កំពត | លោក ភូ គីកុក | 75 | 19 | 96 | 14 | 4.075 | 1.569 | 837 | 150 | 5.083 | 1.752 |
| កណ្ដាល | លោក ទូច សំអឿន | 109 | 26 | 145 | 31 | 7.945 | 3.456 | 1.179 | 251 | 9.378 | 3.764 |
| កែប | លោក ងួន បៀន | 32 | 8 | 18 | 2 | 291 | 102 | 80 | 21 | 421 | 133 |
| កោះកុង | លោក សួន សីហា | 26 | 3 | 37 | 4 | 540 | 137 | 49 | 10 | 652 | 154 |
| ក្រចេះ | លោក គីម ដូ | 51 | 10 | 45 | 10 | 2.117 | 1.025 | 384 | 98 | 2.597 | 1.143 |
| មណ្ឌលគិរី | លោក ទិម សង្វាត | 29 | 4 | 20 | 1 | 255 | 82 | 18 | 7 | 322 | 94 |
| ឧត្ដរមានជ័យ | លោក អ៊ីង បូរ៉ាត់ | 27 | 4 | 35 | 5 | 699 | 138 | 120 | 12 | 881 | 159 |
| ប៉ៃលិន | លោក នួន នីម | 31 | 5 | 16 | 2 | 284 | 93 | 42 | 7 | 373 | 107 |
| ភ្នំពេញ | លោក អ៊ុំ ហឿង | 111 | 32 | 65 | 17 | 8.142 | 4.900 | 1.016 | 440 | 9.334 | 5.389 |
| ព្រះវិហារ | លោក ហន ឆន | 39 | 9 | 46 | 1 | 889 | 278 | 158 | 29 | 1.132 | 317 |
| ព្រៃវែង | លោក ហ៊ុម សុផល | 111 | 35 | 161 | 22 | 5991 | 1822 | 1377 | 219 | 7.640 | 2.098 |
| ពោធិសាត់ | លោក ធាម លិមអៀង | 63 | 14 | 78 | 16 | 2.547 | 873 | 458 | 92 | 3.146 | 995 |
| រតនគិរី | លោក ផាន់ ភីរុណ | 35 | 8 | 18 | 1 | 422 | 125 | 36 | 11 | 511 | 145 |
| សៀមរាប | លោក តោ គីមស៊ាន | 73 | 16 | 108 | 14 | 3.417 | 1.657 | 664 | 195 | 4.262 | 1.882 |
| ក្រុងព្រះសីហនុ | លោកស្រី សឿ ទេពី | 47 | 12 | 27 | 5 | 1.171 | 442 | 202 | 77 | 1.447 | 536 |
| ស្ទឹងត្រែង | លោក ណយ សូខ័ន | 43 | 11 | 26 | 2 | 684 | 273 | 79 | 11 | 832 | 297 |
| ស្វាយរៀង | លោក នាង រី | 71 | 12 | 103 | 11 | 3.512 | 882 | 644 | 86 | 4.330 | 991 |
| តាកែវ | លោក នុត ខុន | 86 | 23 | 124 | 19 | 6.102 | 1.714 | 1.137 | 149 | 7.449 | 1.905 |
| **ទូទាំងប្រទេស** | | 1.534 | 336 | 1.867 | 307 | 77.897 | 31.266 | 14.591 | 3.206 | 95.889 | 35.145 |
| -តំបន់ក្រុង | | 1.534 | 366 | 331 | 77 | 20.277 | 10.853 | 3.340 | 1.334 | 25.482 | 12.630 |
